# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


០៩-០១-២០១៤ -ព្រះរាជក្រម នស/រកម/០១១៤/០០៣ ស្ដីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារ ស្ដីពីការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួន ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ ៧២៦

០៩-០១-២០១៤ -ព្រះរាជក្រម នស/រកម/០១១៤/០០៤ ស្ដីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្ដីពីការអនុម័ត យល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្ដីពីបំលាស់ទីរូបវន្តបុគ្គល ៧៤១


### ២~ព្រះរាជក្រឹត្យ


២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤២៤ ស្ដីពី ការតម្លើងឋានៈទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី ៥ ចំនួន ០៣ រូប ៧៨៥

២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤២៥ ស្ដីពី ការតម្លើងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការ ០២ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ៧៨៦

២៧-១២-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤២៦ ស្ដីពី ការតាំងស៊ប់ជូនមន្ត្រីរាជការ ចំនួន ១១៤ រូប ទៅក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ៧៨៧

២៧-១២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤២៧ ស្ដីពី ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ ចំនួន ១៩ រូប ៧៩២

២៧-១២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤២៨ ស្ដីពី ការតែងតាំងឯកឧត្តម **សួន "រ៉ានី** ជា នាយកការសិក្សា និងកម្មសិក្សា នៃសាលាភូមិន្ទរដ្ឋបាល មានឋានៈស្មើ អគ្គនាយក ជំនួសឯកឧត្តម **ឈឹម ឃីសាង** ដែលត្រូវបានផ្ទេរចេញ ៧៩៤

២៧-១២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤២៩ ស្ដីពី ការតែងតាំងឯកឧត្តម **លឹម គង់** ជា អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ៧៩៥

២៧-១២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៣០ ស្ដីពី ការតែងតាំងទីប្រឹក្សា ក្រុមប្រឹក្សាភិបាល មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ចំនួន ០២ រូប ៧៩៦

## II.រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៦-០១-២០១៤-អនុក្រឹត្យលេខ ០៤ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦៣០,៦១៩៧ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពីដីតម្រូវព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៦៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៧៩៧

០៦-០១-២០១៤-អនុក្រឹត្យលេខ ០៥ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣០,០១៩៥ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីដីតម្រូវព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៨ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៨០៣

០៦-០១-២០១៤-អនុក្រឹត្យលេខ ០៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៨០៧

០៦-០១-២០១៤-អនុក្រឹត្យលេខ ០៧ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៩៩៦,៨៧០៩ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីដីតម្រូវព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤១៣ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៨០៩

០៩-០១-២០១៤-អនុក្រឹត្យលេខ ២៥ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ៨១៤

១០-០១-២០១៤-អនុក្រឹត្យលេខ ២៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨១៦

១០-០១-២០១៤-អនុក្រឹត្យលេខ ២៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨២២

## III.ការិយាល័យក្រសួង

### ទីស្តីការក្រសួងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៥-១២-២០១៣-ប្រកាសលេខ ១៥០០ សហវ.ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៨២៥

# ព្រះរាជក្រម

នស/រកម/០១១៤/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារស្តីពីការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួន ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៤ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារ ស្តីពីការធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួន ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារ ស្តីពីការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួន ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ ដែលបានចុះហត្ថលេខា នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម នាថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារនេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៤

នស.១៤០១.០២៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**អូន ព័ន្ធមុនីរ័ត្ន**

លេខ [illegible] ស.ណ

**សំណៅដែលមានតម្លៃស្មើជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី [illegible]៣ ខែមករា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជាណាចក្រកម្ពុជា

*Royaume du Cambodge*

| | |
|---|---|
| រាជរដ្ឋាភិបាល | ជាតិ សាសនា ព្រះមហាក្សត្រ |
| *Gouvernement Royal* | *Nation Religion Roi* |

លេខ: ១០១. សរ/ប្រ

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាលកម្ពុជា

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ដើម្បីចុះហត្ថលេខា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា លើពិធីសារដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួន ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ (Protocol to Amend Certain ASEAN Economic Agreements Related to Trade in Goods)។

ក្នុងករណីឯកឧត្តម **ចម ប្រសិទ្ធ** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

អាស្រ័យហេតុនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចដែលច្បាប់បានប្រគល់ជូន បានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ពិធីសារ
# ស្តីពីការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួនពាក់ព័ន្ធពាណិជ្ជកម្មទំនិញ

រដ្ឋាភិបាលប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម រដ្ឋសមាជិកនៃប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) (ដែលទាំងអស់ហៅថា " បណ្តារដ្ឋសមាជិក" ឬតែមួយហៅថា "រដ្ឋសមាជិក")

**ដោយទទួលស្គាល់** នូវតម្រូវការក្នុងការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួនពាក់ព័ន្ធពាណិជ្ជកម្មទំនិញ យកចិត្តទុកដាក់លើការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ (ដែលហៅថា "អាទិកា") ដែលបានចុះហត្ថលេខានៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ នៅឆាអាម ថៃ ដែលត្រូវជំនួស ក្នុងចំណោមកិច្ចព្រមព្រៀងទាំងនោះ កិច្ចព្រមព្រៀងស្តីពីកម្មវិធីអនុគ្រោះពន្ធរួមសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ដូចដែលបានធ្វើវិសោធនកម្ម

បានព្រមព្រៀងដូចខាងក្រោម :

## មាត្រា ១

មាត្រា ២(ក)២ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការពង្រឹងសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ានបានចុះហត្ថលេខានៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩២ នៅសិង្ហបុរី ត្រូវបានកែប្រែ ដោយមាត្រាជំនួស ២(ក)២ ដូចខាងក្រោម :

> " ២. កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ាន (អាទិកា) ត្រូវជាយន្តការចម្បងសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន។ ចំពោះផលិតផល ដែលពុំគ្របដណ្តប់ដោយអាទិកា យន្តការដែលបានព្រមព្រៀងផ្សេងទៀតអាចយកមកប្រើ។"

## មាត្រា ២

១. មាត្រា ៦(១) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអ៊ី-អាស៊ាន ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០០ នៅសិង្ហបុរី ត្រូវបានកែប្រែ ដោយមាត្រាជំនួស ៦(១) ដូចខាងក្រោម :

" ១. រដ្ឋសមាជិកត្រូវចូលរួមចរចា ដែលនាំទៅរកការពន្លឿនការសន្យារបស់រដ្ឋសមាជិកពាក់ព័ន្ធនឹងផលិតផលព័ត៌មានបច្ចេកវិទ្យា សេវាព័ត៌មានបច្ចេកវិទ្យា និងវិនិយោគ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសេវា និង កិច្ចព្រមព្រៀងទូលំទូលាយវិនិយោគអាស៊ាន។"

២. មាត្រា ១៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអ៊ី-អាស៊ាន ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ នៅសឹង្ហបុរី បានកែប្រែ ដោយមាត្រាជំនួស ១៤ ដូចខងក្រោម ៖

"លើកលែងតែមានចែងជាក់លាក់ផ្សេងពីកិច្ចព្រមព្រៀងអ៊ី-អាស៊ាន រាល់បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសេវានិងរាល់ពិធីសាររបស់វា និងកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន រាប់បញ្ចូលប៉ុន្តែមិនកំណត់ត្រឹមតែរាល់បទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងវិធានការការពារ និងការលើកលែង មិនត្រូវធ្វើឲ្យខូចខាតដោយកិច្ចព្រមព្រៀងអ៊ី-អាស៊ាន និងត្រូវអនុវត្តទៅលើកិច្ចព្រមព្រៀងអ៊ី-អាស៊ាន។"

## មាត្រា ៣

មាត្រា ៥(១) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសមាហរណកម្មវិស័យអាទិភាព ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅវៀងច័ន្ទ ឡាវភីឌីអ៊ី ដូចដែលបានកែប្រែដោយតាមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៦ នៅស៊ីប៊ូ ហ្វីលីពីន និងបានកែប្រែបន្តទៀត ដោយមាត្រាជំនួស ៥(១) ដូចខាងក្រោម ៖

" ១. រដ្ឋសមាជិកនីមួយៗ ត្រូវលុបពន្ធនាំចូលលើផលិតផលសមាហរណកម្មវិស័យអាទិភាព អនុលោមតាមមាត្រា ១៩(២)(ក)(i) និងមាត្រា ១៩(២)(ក) នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ។"

## មាត្រា ៤

មាត្រា ៣ នៃពិធីសារវិស័យសមាហរណកម្មអាស៊ាន សម្រាប់ផលិតផលកសិកម្ម បានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅវៀងច័ន្ទ ឡាវភីឌីអ៊ី មិនត្រូវយកមកអនុវត្ត។

## មាត្រា ៥

មាត្រា ៣ នៃពិធីសារវិស័យសមាហរណកម្មអាស៊ាន សម្រាប់ផលិតផលយានយន្ត បានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅវៀងច័ន្ទ ឡាវភីឌីអ៊ី មិនត្រូវយកមកអនុវត្ត។

## មាត្រា ៦

មាត្រា ៣ នៃពិធីសារវិស័យសមាហរណកម្មអាស៊ាន សម្រាប់ផលិតផលអ៊ី - អាស៊ាន បានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅវៀងច័ន្ទ ឡាវភីឌីអ៊ី មិនត្រូវយកមកអនុវត្ត។

## មាត្រា៧

មាត្រា ៣ នៃពិធីសារវិស័យសមាហរណកម្មអាស៊ាន សម្រាប់ផលិតផលអេឡិចត្រូនិច បានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅវៀងច័ន្ទ ឡាវភីឌីអ៊ី មិនត្រូវយកមកអនុវត្ត។

២. ពិធីសារនេះ ត្រូវតម្កល់ជាមួយអគ្គលេខាធិការអាស៊ាន ជាអ្នកដែលត្រូវផ្តល់នូវច្បាប់ចម្លងបញ្ជាក់មួយច្បាប់ទៅរដ្ឋសមាជិកនីមួយៗ។

**ជាសក្ខីភាព** អ្នកចុះហត្ថលេខាខាងក្រោមនេះ ដោយត្រូវបានផ្តល់សិទ្ធិពេញលេញដោយរដ្ឋាភិបាលរបស់ពួកគេ បានចុះហត្ថលេខាលើពិធីសារស្តីពីការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួនពាក់ព័ន្ធពាណិជ្ជកម្មទំនិញ។

សម្រាប់រដ្ឋាភិបាលប្រ៊ុយណេដារ៉ូសាឡឹម

លឹម ជក សេង

រដ្ឋមន្ត្រីទី ២ នៃក្រសួងការបរទេស និង ពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលរាជាណាចក្រកម្ពុជា

ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូនេស៊ី

ហ្គីតា អ៊ីរ៉ាវ៉ាន់ វីចាវ៉ាន់
រដ្ឋមន្ត្រីពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតឡាវ

ណាំ វីយ៉ាកេត
រដ្ឋមន្ត្រីឧស្សាហកម្ម និង ពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលម៉ាឡេស៊ី

ម៉ូសតាហ្វា ម៉ូហាម៉េត
រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និង ឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា

បណ្ឌិត. កាន់ ស៊ោវ
រដ្ឋមន្ត្រីសហភាពក្រសួងផែនការ និង អភិវឌ្ឍន៍សេដ្ឋកិច្ច

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

ហ្គ្រេចហ្វូរី អ៊ិល.ដូមិនហ្គូ
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសឹង្ហបុរី

លឹម ហុង គៀង
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលរាជាណាចក្រថៃ

ប៊ូសង តេរីយ៉ាភិរម្យ
រដ្ឋមន្ត្រីពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

វូ ហ៊ុយហ័ង
រដ្ឋមន្ត្រីឧស្សាហកម្ម និង ពាណិជ្ជកម្ម

ព្រះរាជាណាចក្រកម្ពុជា

*Royaume du Cambodge*

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion Roi*

រាជរដ្ឋាភិបាល

*Gouvernement Royal*

N°: 101 D.F.P

Phnom Penh, October 01, 2012

**DELEGATION OF FULL POWER**

- Having seen the constitution of the Kingdom of Cambodia
- Having seen the Royal Decree No. NS/RKT/0908/1055 dated September 25, 2008 on the composition of the Royal Government of Cambodia
- Having seen the Royal Decree No. 02/NS/94 dated July 20, 1994 on the Organization and Functioning of the Council of the Ministers;
- Referring to the request of the Minister of Economy and Finance

**THE ROYAL GOVERNMENT OF CAMBODIA**

Delegates herewith full power to H.E. **CHAM PRASIDH**, Senior Minister, Minister of Commerce and Minister in charge of the ASEAN Economic Minister, to sign, on behalf of the Royal Government of Cambodia, Protocol to Amend Certain ASEAN Economic Agreements Related to Trade in Goods.

This power includes the power of delegation.

In witness whereof, the undersigned, Samdech Akka Moha Sena Padei Techo **HUN SEN**, Prime Minister of the Kingdom of Cambodia, with full power duly entrusted to him, has signed this delegation of full power.

**PRIME MINISTER**

**Samdech Akka Moha Sena Padei Techo HUN SEN**

# PROTOCOL
# TO AMEND CERTAIN ASEAN ECONOMIC AGREEMENTS RELATED TO TRADE IN GOODS

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (ASEAN) (hereinafter collectively referred to as "Member States" or singularly as "Member State");

**RECOGNISING** the need to amend certain ASEAN economic agreements related to trade in goods to take into account the entry into force of the ASEAN Trade in Goods Agreement (hereinafter referred to as "the ATIGA") signed on 26 February 2009 in Cha-am, Thailand, which is intended to supersede, among others, the Agreement on the Common Effective Preferential Tariff Scheme for the ASEAN Free Trade Area as amended;

**HAVE AGREED AS FOLLOWS:**

## ARTICLE 1

Article 2(A)(2) of the Framework Agreement on Enhancing ASEAN Economic Cooperation signed on 28 January 1992 in Singapore shall be amended by substituting Article 2(A)(2) with the following:

"2. The ASEAN Trade in Goods Agreement (ATIGA) shall be the main mechanism for the AFTA. For



CERTIFIED COPY
DEPUTY SECRETARY-GENERAL, THE ... SECRETARIAT

products not covered by the ATIGA, any other agreed mechanism may be used."

**ARTICLE 2**

1. Article 6(1) of the e-ASEAN Framework Agreement signed on 24 November 2000 in Singapore shall be amended by substituting Article 6(1) with the following:

> "1. Member States shall enter into negotiations which shall be directed towards accelerating commitments of the Member States relating to ICT products, ICT services and investments under the ASEAN Trade in Goods Agreement, the ASEAN Framework Agreement on Services and the ASEAN Comprehensive Investment Agreement."

2. Article 14 of the e-ASEAN Framework Agreement signed on 24 November 2000 in Singapore shall be amended by substituting Article 14 with the following:

> "Except as otherwise provided specifically in this Agreement, the provisions of the ASEAN Trade in Goods Agreement, the ASEAN Framework Agreement on Services and its Protocols, and the ASEAN Comprehensive Investment Agreement, including but not limited to the provisions relating to safeguard measures and exceptions, shall not be prejudiced by, and shall apply to, this Agreement."

**ARTICLE 3**

Article 4(1) of ASEAN Framework Agreement for the Integration of Priority Sectors signed on 29 November 2004 in Vientiane, Lao PDR, as amended by the ASEAN Framework (Amendment) Agreement for the Integration of Priority Sectors



CERTIFIED COPY DEPUTY SECRETARY-GENERAL, THE ASEAN SECRETARIAT asean

signed on 8 December 2006 in Cebu, the Philippines, shall be further amended by substituting Article 4(1) with the following:

> "1. Each Member State shall eliminate import duties on Priority Integration Sectors (PIS) products in accordance with Article 19(2)(a)(i) and Article 19(2)(c) of the ASEAN Trade in Goods Agreement."

## ARTICLE 4

Article 3 of the ASEAN Sectoral Integration Protocol for Agro-Based Products signed on 29 November 2004 in Vientiane, Lao PDR shall no longer apply.

## ARTICLE 5

Article 3 of the ASEAN Sectoral Integration Protocol for Automotives signed on 29 November 2004 in Vientiane, Lao PDR shall no longer apply.

## ARTICLE 6

Article 3 of the ASEAN Sectoral Integration Protocol for e-ASEAN signed on 29 November 2004 in Vientiane, Lao PDR shall no longer apply.

## ARTICLE 7

Article 3 of the ASEAN Sectoral Integration Protocol for Electronics signed on 29 November 2004 in Vientiane, Lao PDR shall no longer apply.



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

2. This Protocol shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified copy thereof to each Member State.

IN WITNESS THEREOF, the undersigned, being duly authorised thereto by their respective Governments, have signed the Protocol to Amend Certain ASEAN Economic Agreements Related to Trade in Goods.

DONE at [HA NOI], [VIET NAM], this [EIGHTH] day of [MARCH] in the year Two Thousand and Thirteen, in a single original copy in the English Language.

For the Government of Brunei Darussalam:

**LIM JOCK SENG**
Second Minister of Foreign Affairs and Trade

For the Kingdom of Cambodia:

**CHAM PRASIDH**
Senior Minister and Minister of Commerce

For the Government of the Republic of Indonesia:

**GITA IRAWAN WIRJAWAN**
Minister of Trade

For the Government of the Lao People's Democratic Republic:

**NAM VIYAKETH**
Minister of Industry and Commerce

For the Government of Malaysia:

**MUSTAPA MOHAMED**
Minister of International Trade and Industry

For the Government of the Republic of the Union of Myanmar:

**DR. KAN ZAW**
Union Minister of Ministry of National Planning and Economic Development

For the Government of the Republic of the Philippines:

**GREGORY L. DOMINGO**
Secretary of Trade and Industry

For the Government of the Republic of Singapore:

**LIM HNG KIANG**
Minister for Trade and Industry

For the Government of the Kingdom of Thailand:

**BOONSONG TERIYAPIROM**
Minister of Commerce

For the Government of the Socialist Republic of Viet Nam:

**VU HUY HOANG**
Minister of Industry and Trade

# ព្រះរាជក្រម

នស/រកម/០១១៤/០០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីបំលាស់ទីរូបវន្តបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៤ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីបំលាស់ទីរូបវន្តបុគ្គល

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីបំលាស់ទីរូបវន្តបុគ្គល ដែលបានចុះហត្ថលេខា នៅរាជធានីភ្នំពេញ នាថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤

នស/រកម/០១១៤/០២៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ហត្ថលេខា**
**អ៊ិត សំហេង**

លេខៈ ៤.៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:១០៩. សរប

*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១២*

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

ប្រទានសិទ្ធិជូនឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីបំលាស់ទីរូបវន្តបុគ្គល។

ក្នុងករណីដែលឯកឧត្តម **ចម ប្រសិទ្ធ** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បកប្រែក្រៅផ្លូវការ

# កិច្ចព្រមព្រៀងអាស៊ានស្តីពីបំលាស់ទីរូបវន្តបុគ្គល

រដ្ឋាភិបាលប្រុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហព័ន្ធមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ សាធារណរដ្ឋសង្គមនិយមវៀតណាម រដ្ឋទាំងឡាយជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅជារួមថារដ្ឋជាសមាជិក ឬហៅដោយឡែកថា រដ្ឋជាសមាជិកនីមួយៗ

**ដោយកត់សំគាល់** ពីគោលការណ៍ណែនាំរបស់ផែនការគោលសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលបានអនុម័តនាកិច្ចប្រជុំកំពូលអាស៊ានលើកទី១៣ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅប្រទេសសិង្ហបុរីថា លំហូរដោយសេរីនៃកម្មករជំនាញ គឺជាសារធាតុដ៏សំខាន់មួយនៃមូលដ្ឋានផលិតកម្ម និងជាទីផ្សាររួមរបស់អាស៊ាន ដែលអនុញ្ញាតិឱ្យមានការបំលាស់ទី ឬការសម្រួលការហូរចូលនៃបំលាស់ទីរូបវន្តបុគ្គល ពាក់ព័ន្ធនិងការធ្វើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ ស្របតាមបញ្ញាតិរបស់ប្រទេសជាអ្នកទទួល

**ដោយរំលឹកឡើងវិញ** ពីកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នាទីក្រុងបាងកក ប្រទេសថៃ និងពិធីសារអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ដែលដាក់ចេញជាមូលដ្ឋានគ្រឹះសម្រាប់ការលុបបំបាត់ចោលការរឹតត្បិតនានាចំពោះពាណិជ្ជកម្មសេវាកម្មក្នុងចំណោមរដ្ឋជាសមាជិកទាំងឡាយលើគ្រប់ម៉ូតនៃចង្វាក់ផ្គត់ផ្គង់សេវាកម្ម រួមទាំងម៉ូត៤ (Mode 4) (បំលាស់ទីរូបវន្តបុគ្គល)

**ដោយមានបំណង** ឱ្យមានយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើសេរីភាវូបនីយកម្មបន្ថែមទៀត និងដើម្បីសម្រួលបំលាស់ទីរូបវន្តបុគ្គលឆ្ពោះទៅរកលំហូរដោយសេរីនៃកម្មករជំនាញក្នុងតំបន់អាស៊ាន តាមរយៈការធ្វើកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នពាក់ព័ន្ធរបស់អាស៊ាន ដោយមិនមានការរឹតត្បិតចំពោះការធ្វើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម វិនិយោគ អន្តោប្រវេសន៍ និងការងារ

**ដោយមានបំណង** ដើម្បីលុបបំបាត់ជាបណ្តើរៗនូវការរិតត្បិតទាំងអស់ ក្នុងបំលាស់ទីឆ្លងកាត់ព្រំដែនរបស់រូបវន្តបុគ្គល ពាក់ព័ន្ធក្នុងបញ្ញត្តិពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ ក្រោមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ

**បានព្រមព្រៀង** ដូចតទៅ ៖

## មាត្រា១
## គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បី ៖

(ក) ផ្តល់វិសាលភាពនៃកិច្ចព្រមព្រៀងអំពីសិទ្ធិ និងកាតព្វកិច្ចបន្ថែមទៅអ្វីដែលមានចែងក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម និងពិធីសារសម្រាប់អនុវត្តក្នុងកិច្ចព្រមព្រៀងនោះ ពាក់ព័ន្ធនិងបំលាស់ទីរូបវន្តបុគ្គលរវាងរដ្ឋជាសមាជិកទាំងឡាយ

(ខ) សម្រួលការបំលាស់ទីរបស់រូបវន្តបុគ្គល ពាក់ព័ន្ធនិងការធ្វើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ រវាងរដ្ឋជាសមាជិកទាំងឡាយ

(គ) បង្កើតនិតិវិធីប្រកបដោយតម្លាភាព សម្រាប់ការដាក់ពាក្យសុំបែបបទអន្តោប្រវេសន៍សម្រាប់ការចូលមក និងស្នាក់នូវជាបណ្តោះអាសន្នរបស់រូបវន្តបុគ្គលដែលកិច្ចព្រមព្រៀងនេះ បានចែង

(ឃ) ការពារបូរណភាពព្រំដែនរបស់រដ្ឋជាសមាជិកទាំងឡាយ និងការពារកំលាំងពលកម្មក្នុងស្រុក ដែលបម្រើការជាអចិន្ត្រៃយ៍ក្នុងដែនដីរបស់រដ្ឋជាសមាជិកទាំងឡាយ ។

## មាត្រា២
## វិសាលភាព

១ កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តលើវិធានការដែលប៉ះពាល់លើការចូលមក ឬការស្នាក់នៅជាបណ្តោះអាសន្ន របស់រូបវន្តបុគ្គលរបស់រដ្ឋជាសមាជិកមួយ ទៅកាន់ដែនដីនៃរដ្ឋជាសមាជិកដទៃទៀត។ រូបវន្តបុគ្គលបែបនេះ រួមមាន ៖

(ក) អ្នកចូលមកធ្វើទស្សនៈកិច្ចក្នុងបំណងដើម្បីធ្វើពាណិជ្ជកម្ម (Business Visitors)

(ខ) អ្នកជំនាញបច្ចេកទេសជាន់ខ្ពស់ ដែលចូលមកបំរើការបណ្តោះអាសន្ន (Intra Corporate Transferees)

(គ) អ្នកផ្គត់ផ្គង់សេវាដែលជាប់កិច្ចសន្យា (Contractual Service Suppliers)

(ឃ) ប្រភេទបុគ្គលដទៃទៀត ដែលអាចមានចែងក្នុងតារាងសន្យាចំពោះការចូលមក និងការស្នាក់នៅបណ្តោះអាសន្នរបស់រូបវន្តបុគ្គលរបស់រដ្ឋជាសមាជិក

២. កិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តលើវិធានការដែលប៉ះពាល់ដល់រូបវន្តបុគ្គលដែលស្វែងរកទីផ្សារការងារក្នុងរដ្ឋជាសមាជិកដទៃទៀត តែត្រូវតែអនុវត្តលើវិធានការពាក់ព័ន្ធនិងការស្វែងរកសញ្ជាតិ និវេសដ្ឋាន ឬការបម្រើការជាអចិន្ត្រៃយ៍ ។

៣. គ្មានអ្វីក្នុងកិច្ចព្រមព្រៀងនេះ រារាំងរដ្ឋសមាជិកមិនឱ្យអនុវត្តវិធានការ ដើម្បីដាក់ចេញជាបញ្ញត្តិលើការចូលមក និងការស្នាក់នៅជាបណ្តោះអាសន្នរបស់រូបវន្តបុគ្គលរបស់រដ្ឋសមាជិកដទៃទៀត ក្នុងដែនដីរបស់ខ្លួនឡើយ ដោយរួមមានវិធានការទាំងឡាយចាំបាច់ដើម្បីការពារបូរណភាពដែនដីរបស់ខ្លួន និងវិធានការដើម្បីធានាឱ្យមានរបៀបរៀបរយនូវបំលាស់ទីរបស់រូបវន្តបុគ្គលឆ្លងកាត់ព្រំដែនរបស់ខ្លួន ដោយចែងថា វិធានការបែបនេះមិនអនុវត្តតាមរបៀបដើម្បីធ្វើមោឃៈភាព ឬដើម្បីធ្វើឱ្យខូចផលប្រយោជន៍ បន្ថែមលើរដ្ឋសមាជិកដទៃទៀត ក្រោមល័ក្ខខ័ណ្ឌនៃការសន្យាជាក់លាក់ ។

៤. ហេតុការតែមួយគត់ ដែលតម្រូវឱ្យរូបវន្តបុគ្គល ដើម្បីបំពេញឱ្យបានតាមបែបបទសុំទិដ្ឋាការមុនពេលចូលទៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ មិនត្រូវចាត់ទុកថាធ្វើឱ្យមោឃៈភាព ឬខូចផលប្រយោជន៍ក្រោមកិច្ចព្រមព្រៀងនេះទេ ។

## មាត្រា៣
## និយមន័យ

ចំពោះបំណងនៃកិច្ចព្រមព្រៀងនេះ និយមន័យដូចខាងក្រោម ត្រូវបានអនុវត្ត ៖

(ក) អ្នកចូលមកធ្វើទស្សនៈកិច្ចក្នុងបំណងធ្វើពាណិជ្ជកម្ម (Business Visitors) មានន័យថា ជារូបវន្តបុគ្គលដែលស្វែងរកការចូលមក ឬការស្នាក់នៅជាបណ្តោះអាសន្នក្នុងដែនដីនៃរដ្ឋជាសមាជិកដទៃទៀត ដែលលាភការ និងការគាំទ្រផ្នែកហិរញ្ញវត្ថុ ក្នុងកំឡុងពេលនៃការធ្វើទស្សនៈកិច្ចរបស់គេបានមកពីខាងក្រៅ នៃរដ្ឋជាសមាជិកដទៃទៀត;

(i) គឺជាតំណាងអ្នកលក់ទំនិញ ឬអ្នកផ្គត់ផ្គង់សេវាកម្ម ដែលមានបំណងចរចាលើការលក់ទំនិញ ឬការផ្គត់ផ្គង់សេវា ឬការចូលចរចាទៅក្នុងកិច្ចព្រមព្រៀងដើម្បីលក់ទំនិញ ឬផ្គត់ផ្គង់សេវា សម្រាប់អ្នកលក់ទំនិញ ឬ

ផ្គត់ផ្គង់សេវា ដែលការចរចានេះមិនពាក់ព័ន្ធនិងការលក់ទំនិញ ឬការផ្គត់ផ្គង់សេវាដោយផ្ទាល់ ទៅឱ្យសាធារណជនទេ

(ii) គឺជានិយោជិកនៃនីតិបុគ្គល ដែលបានកំណត់ក្នុងអនុកថាខ័ណ្ឌ(i), (ii)និង (iii) នៃមាត្រានេះ សម្រាប់តែគោលបំណងបង្កើតវិនិយោគទុន ឬបង្កើតការិយាល័យតំណាងពាណិជ្ជកម្ម ចំពោះនីតិបុគ្គលក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត

(iii) សម្រាប់គោលបំណងនៃការចូលរួមក្នុងកិច្ចប្រជុំ ឬ ការចរចាពាណិជ្ជកម្ម ឬ

(iv) សម្រាប់គោលបំណងនៃការបង្កើតវិនិយោគទុន ឬបង្កើតការិយាល័យតំណាងពាណិជ្ជកម្ម ក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត

(ខ) អ្នកផ្គត់ផ្គង់សេវាដែលជាប់កិច្ចសន្យា (Contractual Service Supplier) មានន័យថា ជារូបវន្តបុគ្គលដែលជានិយោជិករបស់នីតិបុគ្គល ដែលបានបង្កើតឡើងក្នុងដែនដីនៃរដ្ឋសមាជិកមួយ ដែលមិនមានការិយាល័យតំណាងពាណិជ្ជកម្មក្នុងដែនដីនៃរដ្ឋជាសមាជិកផ្សេងទៀត ហើយដែលសេវានឹងផ្តល់ជូនចំពោះទៅ ៖

(i) ការចូលដែនដីនៃរដ្ឋសមាជិកផ្សេងទៀតនោះ ដើម្បីផ្គត់ផ្គង់សេវាអនុលោមតាមកិច្ចសន្យា រវាងនិយោជករបស់គាត់ និងអ្នកប្រើប្រាស់សេវារបស់គាត់ក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត

(ii) គឺជាអ្នកប្រតិបត្តិការ អ្នកគ្រប់គ្រង ឬអ្នកឯកទេសដែលបានកំណត់ក្នុងអនុកថាខ័ណ្ឌ(i), (ii) និង (iii) នៃមាត្រានេះដែលទទួលលាភការពីនិយោជករបស់គាត់

(iii) ត្រូវមានគុណសម្បត្តិផ្នែកវិជ្ជាជីវៈ និងកំរិតអប់រំសមស្របពាក់ព័ន្ធនិងសេវាដែលត្រូវផ្តល់ជូន

(iv) អាចនឹងត្រូវអនុវត្តថា ជានិយោគជិករបស់នីតិបុគ្គលបម្រើការក្នុងរយៈពេលណាមួយ ដែលអាចមានចែងក្នុងតារាងសន្យា

(គ) រដ្ឋសមាជិកដែលផ្តល់ការអនុញ្ញាតិឱ្យ (Granting Member State) មានន័យថា ជារដ្ឋសមាជិកមួយដែលទទួលការដាក់ពាក្យស្នើសុំសម្រាប់ការចូលមក ឬស្នាក់នៅជាបណ្តោះអាសន្ន ពីរូបវន្តបុគ្គលរបស់រដ្ឋជាសមាជិកផ្សេងទៀត ដែលមានចែងក្នុងមាត្រា ២ (វិសាលភាព)

(ឃ) បែបបទអន្តោប្រវេសន៍ (Immigration Formality) មានន័យថាជាទិដ្ឋាការ លិខិតអនុញ្ញាតិ ប័ណ្ណអនុញ្ញាតិចេញ-ចូល ឬឯកសារដទៃទៀត ឬការផ្តល់ការអនុញ្ញាតិជូនតាមអេឡិចត្រូនិច ដល់រូបវន្តបុគ្គលរបស់រដ្ឋជាសមាជិកមួយ

នូវសិទ្ធិដើម្បីចូលមកស្នាក់នៅ ឬធ្វើការបណ្តោះអាសន្ន ឬដើម្បីបង្កើតការិយាល័យតំណាងពាណិជ្ជកម្ម ក្នុងដែនដីនៃរដ្ឋសមាជិកដែលផ្តល់ការអនុញ្ញាតិជូននោះ

(ង) អ្នកជំនាញបច្ចេកទេសជាន់ខ្ពស់ ដែលចូលមកបំរើការបណ្តោះអាសន្ន (Intra-Corporate Transferee) មានន័យថា រូបវន្តបុគ្គលដែលជានិយោជិករបស់នីតិបុគ្គល ដែលបានបង្កើតក្នុងដែនដីរបស់រដ្ឋជាសមាជិកមួយដែលបានផ្ទេរការផ្គត់ផ្គង់សេវាបណ្តោះអាសន្ន តាមរយៈការិយាល័យតំណាងពាណិជ្ជកម្ម (ការិយាល័យតំណាងសាខា) ក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត និងដែលត្រូវបានបម្រើជានិយោជិករបស់នីតិបុគ្គលក្នុងកំឡុងពេលណាមួយដែលអាចកំណត់ក្នុងតារាងសន្យា និងដែលជា ៖

(i) ប្រតិបត្តិករ (Executive) ជារូបវន្តបុគ្គលក្នុងស្ថាប័ន ដែលដឹកនាំការគ្រប់គ្រងស្ថាប័នជាចំបង ហើយដែលអនុវត្តសេរីភាពនៃការសម្រេចចិត្តទូលំទូលាយ ដោយទទួលការគ្រប់គ្រង និងទទួលទិសដៅពីប្រតិបត្តិករជាន់ខ្ពស់ ក្រុមប្រឹក្សានាយក ឬពីម្ចាស់ភាគហ៊ុនពាណិជ្ជកម្ម ដែលមិនបំពេញការងារពាក់ព័ន្ធផ្ទាល់ទៅនិងបញ្ញត្តិសេវាកម្ម ឬ សេវាកម្មរបស់ស្ថាប័ន

(ii) អ្នកគ្រប់គ្រង (Manager) ជារូបវន្តបុគ្គលក្នុងស្ថាប័នដែលដឹកនាំស្ថាប័នការិយាល័យឬផ្នែកមួយៗ ហើយអនុវត្តការត្រួតពិនិត្យលើផ្នែកដទៃទៀត ឬលើបុគ្គលិកជំនាញ តែមិនគ្រប់គ្រងលើនិយោជិកដែលបំពេញការងារជាចំបង និងចាំបាច់សម្រាប់បទបញ្ញត្តិសេវាកម្មឡើយ

(iii) អ្នកឯកទេស (Specialist) ជារូបវន្តបុគ្គលក្នុងស្ថាប័ន ដែលមានចំណេះដឹងក្នុងកំរិតឯកទេសជាន់ខ្ពស់ ចាំបាច់ដើម្បីបង្កើតបញ្ញត្តិសេវាកម្មឬដែលមានចំណេះដឹងជាកម្មសិទ្ធិរបស់ សេវាស្ថាប័ន ជាអ្នកស្រាវជ្រាវ ជាអ្នកបច្ចេកទេស ឬជាការគ្រប់គ្រង ដែលអាចរាប់បញ្ចូល ប៉ុន្តែមិនកំណត់ចំពោះ សមាជិកអ្នកឯកទេសដែលមានអាជ្ញាប័ន

(ច) រូបវន្តបុគ្គល (Natural Person) មានន័យថា ជារូបវន្តបុគ្គលដែលជាជនជាតិរបស់រដ្ឋជាសមាជិកមួយស្របតាមច្បាប់បញ្ញត្តិ និងគោលនយោបាយរបស់ជាតិ និង

(ឆ) ការចូលមក និងស្នាក់នៅជាបណ្តោះអាសន្ន (Temporary Entry or Temporary Stay) មានន័យថា ការចូលទៅក្នុង ឬការស្នាក់នៅរបស់រូបវន្តបុគ្គល ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ដោយមិនមានបំណងដើម្បីបង្កើតការស្នាក់នៅជាអចិន្ត្រៃយ៍ ។

## មាត្រា៤
## ការផ្តល់ការអនុញ្ញាតឱ្យចូលមកបណ្តោះអាសន្ន ឬ ការស្នាក់នៅបណ្តោះអាសន្ន

១. រដ្ឋសមាជិកនីមួយៗ ផ្អែកតាមតារាងនៃការសន្យារបស់ខ្លួនដូចមានចែងនៅក្នុង ឧបសម្ព័ន្ធ១ ត្រូវផ្តល់ការអនុញ្ញាតឱ្យចូលមកបណ្តោះអាសន្ន ឬការស្នាក់នៅបណ្តោះអាសន្ន ស្របតាមកិច្ចព្រមព្រៀងនេះ ចំពោះរូបវន្តបុគ្គលរបស់រដ្ឋសមាជិកមួយទៀត ក្នុងលក្ខខណ្ឌដែលរូបវន្តបុគ្គលនោះ

(ក) គោរពតាមនីតិវិធីនៃការដាក់ពាក្យសុំសម្រាប់បែបបទអន្តោប្រវេសន៍ ដែលខ្លួនស្នើសុំ និង

(ខ) បំពេញបាននូវគ្រប់លក្ខណៈសម្បត្តិទាំងអស់ដែលតម្រូវឱ្យមាន ដោយរដ្ឋសមាជិកដែលផ្តល់ការអនុញ្ញាតឱ្យចូលមកបណ្តោះអាសន្ន ឬស្នាក់នៅបណ្តោះអាសន្ន។

២. រាល់កម្រៃដែលយក ពាក់ពន្ធ័នឹងការពិនិត្យបែបបទអន្តោប្រវេសន៍ ត្រូវមានបរិមាណសមរម្យ និងស្របតាមច្បាប់ក្នុងស្រុក។

៣. រដ្ឋសមាជិកមួយ អាចបដិសេធការចូលមកបណ្តោះអាសន្ន ឬការស្នាក់នៅបណ្តោះអាសន្ន ចំពោះរូបវន្តបុគ្គលរបស់រដ្ឋសមាជិកមួយទៀតដែលមិនគោរពតាមវាក្យខណ្ឌ ១(ក) និង ១(ខ) នៃមាត្រានេះ។

## មាត្រា៥
## ការពិនិត្យពាក្យសុំ

១. នៅទីណាដែលពាក្យសុំសម្រាប់បែបបទអន្តោប្រវេសន៍ ត្រូវបានតម្រូវដោយរដ្ឋសមាជិកមួយ រដ្ឋសមាជិកនោះត្រូវពិនិត្យជាបន្ទាន់នូវពាក្យសុំសម្រាប់បែបបទអន្តោប្រវេសន៍ ឬពាក្យសុំពន្យាដែលបានបំពេញរួចរាល់ ដែលទទួលបានពីរូបវន្តបុគ្គលនៃរដ្ឋសមាជិកមួយទៀត ស្ថិតក្រោមមាត្រា២ (វិសាលភាព)។

២. រដ្ឋសមាជិកនីមួយៗនៅពេលទទួលបានការស្នើសុំ និងស្ថិតក្នុងអំឡុងពេលមួយសមស្រប បន្ទាប់ពីបានទទួលនូវពាក្យសុំសម្រាប់ប៉ែបបទអន្តោប្រវេសន៍ដែលបានបំពេញរួចរាល់ពីរូបវន្តបុគ្គលនៃរដ្ឋសមាជិកមួយទៀត ដែលស្ថិតក្រោមមាត្រា២ (វិសាលភាព) ត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំអំពីៈ

(ក) ការទទួលយកពាក្យសុំ

(ខ) ស្ថានភាពនៃពាក្យសុំ និង

(គ) សេចក្តីសម្រេចពាក់ព័ន្ធនឹងពាក្យសុំ ហើយក្នុងករណីយល់ព្រមលើពាក្យសុំ ត្រូវប្រាប់អំពីរយៈពេលដែលអនុញ្ញាតឱ្យស្នាក់នៅ និងលក្ខខណ្ឌដទៃទៀត ។

៣. ក្នុងករណីពាក្យសុំមិនបានបំពេញសព្វគ្រប់ ផ្អែកតាមសំណើរបស់អ្នកដាក់ពាក្យសុំ រដ្ឋសមាជិកត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំ នូវរាល់ព័ត៌មានបន្ថែមទាំងអស់ដែលតម្រូវឱ្យមានសម្រាប់បំពេញពាក្យសុំ និងត្រូវផ្តល់ឱកាសដល់អ្នកដាក់ពាក្យសុំក្នុងការប៉ះប៉ូវនូវគារខ្វះខាតដែលមាននៅក្នុងពាក្យសុំរបស់ខ្លួន។

## មាត្រា៦
## តារាងនៃការសន្យាសម្រាប់ការចូលមកបណ្តោះអាសន្ន និងការស្នាក់នៅបណ្តោះអាសន្ន

១. រដ្ឋសមាជិកនីមួយៗ ត្រូវដាក់នៅក្នុងឧបសម្ព័ន្ធ១ នូវតារាងនៃការសន្យារបស់ខ្លួនសម្រាប់ការចូលមកបណ្តោះអាសន្ន ឬការស្នាក់នៅបណ្តោះអាសន្ននៅក្នុងដែនដីរបស់ខ្លួននៃរូបវន្តបុគ្គលរបស់រដ្ឋសមាជិកផ្សេងទៀត ដែលស្ថិតនៅក្នុងមាត្រា២ (វិសាលភាព)។ តារាងនៃការសន្យាទាំងនេះត្រូវចែងអំពីលក្ខខណ្ឌ និងដែនកំណត់ទូទៅសម្រាប់ការសន្យាទាំងនោះ ដោយរួមបញ្ចូលនូវអំឡុងពេលសម្រាប់ការស្នាក់នៅសម្រាប់ប្រភេទនីមួយៗនៃរូបវន្តបុគ្គល ដែលមានចែងនៅក្នុងតារាងនៃការសន្យារបស់រដ្ឋសមាជិក នីមួយៗ។

២. នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន តារាងនៃការសន្យាដូចមានចែងនៅក្នុងវាក្យខណ្ឌ១ នៃមាត្រានេះ ត្រូវមានអនុភាពលុបលើការសន្យានានាដែលបានធ្វើឡើងនៅក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ាន ស្តីពីសេវាកម្មដែលពាក់ព័ន្ធនឹងម៉ូដ៤ (បំលាស់ទីនៃរូបវន្តបុគ្គល) ។

## មាត្រា៧
## សេរីភាវូបនីយកម្មបន្ថែម

១. រដ្ឋសមាជិកត្រូវចូលរួមពិភាក្សា ដើម្បីត្រួតពិនិត្យឡើងវិញនូវតារាងនៃការសន្យានៅក្រោមកិច្ចព្រមព្រៀងនេះ សំដៅឈានទៅសម្រេចនូវសេរីភាវូបនីយកម្មស្តីពីបំលាស់ទីរូបវន្តបុគ្គល។ ការពិភាក្សាលើកដំបូង ដើម្បីត្រួតពិនិត្យឡើងវិញនូវតារាងនៃការសន្យា ត្រូវធ្វើឡើងក្នុងអំឡុងពេលមួយឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀង

នេះ។ ការពិភាក្សាជាបន្តទៀត ត្រូវធ្វើឡើងក្នុងអំឡុងពេលមួយ ផ្អែកទៅតាមការឯកភាពគ្នារបស់រដ្ឋសមាជិក។

២. ការកែសម្រួលតារាងនៃការសន្យា បានមកពីលទ្ធផលនៃការពិភាក្សាគ្នា ដែលបាននិយាយយោងដល់ក្នុងវាក្យខណ្ឌ១ នៃមាត្រានេះ នឹងត្រូវបានច្របាច់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ ផ្អែកតាមវាក្យខណ្ឌ២ ៣ ៤ និង៥ នៃមាត្រា១៥ (ការកែសម្រួល ការកែប្រែ និងការធ្វើវិសោធនកម្ម)។

## មាត្រា៨
## តម្លាភាព

រដ្ឋសមាជិកនីមួយៗ ត្រូវ:

(ក) បោះផ្សាយ ឬធ្វើឱ្យមានជាសាធារណៈនូវឯកសារពន្យល់ស្តីពីបែបបទអន្តោប្រវេសន៍ទាំងអស់ដែលពាក់ព័ន្ធ ឬជះឥទ្ធិពលដល់ដំណើរការនៃការអនុវត្តកិច្ចព្រមព្រៀងនេះ

(ខ) រក្សាទុក ឬបង្កើតចំណុចទំនាក់ទំនង ឬយន្តការដទៃទៀត ដើម្បីឆ្លើយតបចំពោះការសាកសួរពីបុគ្គលដែលមានការពាក់ព័ន្ធ ស្តីពីបទបញ្ញត្តិនានាដែលជះឥទ្ធិពលដល់ការចូលមកបណ្តោះអាសន្ន ឬការស្នាក់នៅបណ្តោះអាសន្ននៃរូបវន្តបុគ្គល

(គ) ប្រសិនបើអាច គួរផ្តល់នូវចន្លោះពេលសមស្របមួយ រវាងការបោះពុម្ពផ្សាយនូវបទបញ្ញត្តិថ្មីៗ ដែលជះឥទ្ធិពលដល់ការចូលមកបណ្តោះអាសន្ន ឬស្នាក់នៅបណ្តោះអាសន្ននៃរូបវន្តបុគ្គល និងកាលបរិច្ឆេទនៃការចូលជាធរមាននៃបទបញ្ញត្តិថ្មីទាំងនោះ។ ការបោះពុម្ពផ្សាយនោះ គួរអាចរកបានក្នុងទម្រង់អេឡិចត្រូនិក។

(ឃ) មិនឱ្យយឺតជាងប្រាំមួយខែ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ត្រូវធ្វើការបោះផ្សាយតាមរយៈគេហទំព័រអន្តោប្រវេសន៍ ឬធ្វើឱ្យអាចរកបានជាសាធារណៈនៅក្នុងដែនដីរបស់ខ្លួន និងអាចរកបានដោយបុគ្គលនានានៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត នូវលក្ខខណ្ឌតម្រូវទូទៅសំរាប់ការចូលមកបណ្តោះអាសន្ន ឬការស្នាក់នៅបណ្តោះអាសន្ន នៅក្រោមកិច្ចព្រមព្រៀងនេះ ដោយរួមបញ្ចូលនូវឯកសារពន្យល់ និងទម្រង់បែបបទនិងឯកសារពាក់

ព័ន្ធដែលនឹងផ្តល់លទ្ធភាពឱ្យរូបវន្តបុគ្គលនៃរដ្ឋសមាជិកផ្សេងទៀតស្គាល់នូវលក្ខខណ្ឌតម្រូវទាំងនោះ និង

(ង) នៅពេលមានការកែប្រែ ឬការធ្វើវិសោធនកម្មវិធានការអន្តោប្រវេសន៍ណាមួយដែលជះឥទ្ធិពលដល់ការចូលមកបណ្តោះអាសន្ន ឬការស្នាក់នៅបណ្តោះអាសន្ន ត្រូវធ្វើការផ្សព្វផ្សាយនូវព័ត៌មាននោះ ឬធ្វើឱ្យអាចរកបានស្របតាមវាក្យខណ្ឌរង(ឃ) នៃមាត្រានេះ ដោយត្រូវធ្វើបច្ចុប្បន្នភាពឱ្យបានឆាប់តាមដែលអាចធ្វើទៅបានក្នុងអំឡុងពេល ៩០ថ្ងៃ។

## មាត្រា៩
## ការលើកលែងទូទៅ

ផ្អែកតាមលក្ខខណ្ឌតម្រូវ វិធានការទាំងនោះ មិនត្រូវបានអនុវត្តន៍នៅក្នុងលក្ខណៈមួយដែលនឹងបង្កើតជាមធ្យោបាយ សម្រាប់ការរើសអើងមិនស្មើភាព ឬគ្មានយុត្តិកម្មរវាងរដ្ឋសមាជិកដែលមានលក្ខខណ្ឌដូចគ្នា ឬបង្កើតឱ្យមានការរឹតត្បិតក្លែងក្លាយចំពោះបំលាស់ទីរូបវន្តបុគ្គល ពុំមានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវបកស្រាយដើម្បីទប់ស្កាត់មិនឱ្យអនុម័ត ឬអនុវត្តន៍ដោយរដ្ឋសមាជិកណាមួយ នូវវិធានការនានាដែល៖

(ក) ចាំបាច់សម្រាប់ការពារសីលធម៌សាធារណៈ ឬការពារសណ្តាប់ធ្នាប់សាធារណៈ[1]

(ខ) ចាំបាច់សំរាប់ការពារជីវិត ឬសុខភាពមនុស្ស សត្វ ឬរុក្ខជាតិ

(គ) ចាំបាច់សម្រាប់ធានានូវសង្គតិភាពជាមួយច្បាប់ ឬបទបញ្ញត្តិនានាដែលមិនស្របជាមួយបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ រួមបញ្ចូលនូវច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹង៖

(i) ការទប់ស្កាត់នូវការបោកបញ្ឆោត និងក្លែងបន្លំ ឬទប់ស្កាត់ចំពោះបច្ច័យអាក្រក់នៃការខកខានមិនបានអនុវត្តកិច្ចសន្យាសេវាកម្ម

(ii) ការពារឯកជនភាពនៃបុគ្គលម្នាក់ៗ ពាក់ព័ន្ធនឹងការពិនិត្យពាក្យស្នើសុំ និងការផ្សព្វផ្សាយទិន្នន័យបុគ្គល និងការពារការសំងាត់នៃសំណុំឯកសារ និងគណនីរបស់បុគ្គលនីមួយៗ។

(iii) សុវត្ថិភាព។

---

[1] ការលើកលែងសម្រាប់សណ្តាប់ធ្នាប់សាធារណៈ អាចត្រូវបានធ្វើឡើង តែនៅពេលណាដែលមានការគំរាមកំហែងធ្ងន់ធ្ងរពិតប្រាកដ និងគ្រប់គ្រាន់ចំពោះផលប្រយោជន៍ជាឫសគល់ណាមួយនៅក្នុងសង្គមប៉ុណ្ណោះ។

## មាត្រា១០
## ការលើកលែងសម្រាប់មូលហេតុសន្តិសុខ

១. មិនមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលត្រូវបកស្រាយដើម្បី៖

(ក) តម្រូវឱ្យរដ្ឋសមាជិកណាមួយ ផ្តល់នូវព័ត៌មានណាមួយ ដែលការលាតត្រដាងព័ត៌មានបែបនេះ ត្រូវបានពិចារណាថាផ្ទុយនឹងផលប្រយោជន៍សន្តិ-សុខរបស់រដ្ឋជាសមាជិកនោះ ឬ

(ខ) បង្ការកុំឱ្យរដ្ឋជាសមាជិកណាមួយ ចាត់វិធានការដែលគិតថាចាំបាច់សម្រាប់ការពារផលប្រយោជន៍សន្តិសុខរបស់ខ្លួន ដែល៖

(i) ទាក់ទិននឹងការផ្គត់ផ្គង់សេវាដែលបានអនុវត្តដោយផ្ទាល់ ឬប្រយោលសម្រាប់គោលបំណងផ្គត់ផ្គង់ដល់អង្គភាពយោធា។

(ii) ទាក់ទិននឹងសម្ភារដែលអាចបំបែក ឬរំលាយសារធាតុអាតូម៉ិចឬសម្ភារដែលកើតចេញមកពីនេះ

(iii) ក្នុងពេលមានសង្គ្រាម ឬគ្រោះអាសន្ននានានៅក្នុងទំនាក់ទំនងអន្តរជាតិ ឬ

(គ) រាំងរដ្ឋជាសមាជិកណាមួយ មិនឱ្យចាត់វិធានការណាមួយ ដែលអនុលោមតាមកាតព្វកិច្ចរបស់ខ្លួន នៅក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិសម្រាប់ការថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

២. រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ត្រូវជូនព័ត៌មានតាមដែលអាចធ្វើបានឱ្យអស់ពីលទ្ធភាពរបស់ខ្លួនអំពីវិធានការ ដែលធ្វើឡើងក្រោមកថាខ័ណ្ឌ ១(ក) និង (គ) នៃមាត្រានេះ។

## មាត្រា១១
## ការដោះស្រាយវិវាទ

១. រដ្ឋជាសមាជិកទាំងអស់ ត្រូវខិតខំប្រឹងប្រែងដោះស្រាយបញ្ហាផ្សេងៗគ្នា ដែលកើតឡើងពីការអនុវត្តន៍កិច្ចព្រមព្រៀងនេះ តាមរយៈការពិគ្រោះយោបល់គ្នា។

២. រដ្ឋជាសមាជិកណាមួយ មិនត្រូវសើរើពិធីសាររបស់អាស៊ានស្តីពីការពង្រឹងយន្តការដោះស្រាយវិវាទដែលបានចុះហត្ថលេខានៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ហើយដែលបានធ្វើវិសោធនកម្មកន្លងមកនោះទេ ដរាបណា

មិនមានការពាក់ពន្ធ័នឹងការបដិសេធការផ្តល់ឱ្យចូលមក ឬស្នាក់នៅបណ្តោះអាសន្ន ក្រោមកិច្ចព្រមព្រៀងនេះ ដូចជា៖

(ក) បញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តន៍ លើផ្នែកណាមួយរបស់រដ្ឋសមាជិក ដែលផ្តល់សិទ្ធិជូន និង

(ខ) រូបវន្តបុគ្គលដែលទទួលរងផលប៉ះពាល់ ហើយដែលប្រើប្រាស់អស់លទ្ធភាពលើដំណោះស្រាយក្នុងស្រុក ក្នុងការដោះស្រាយវិវាទ។

## មាត្រា១២
## ទំនាក់ទំនងជាមួយនឹងកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

១. កិច្ចព្រមព្រៀងនេះ មិនជាប់ទាក់ទងនឹងវិធានការនានាដែលបានអនុម័ត ឬការពារដោយរដ្ឋសមាជិកនីមួយៗ ដើម្បីដាក់បញ្ចូលឱ្យគ្របដណ្តប់ដោយកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន (ACIA) នោះទេ។

២. អ្វីដែលផ្ទុយនឹងកថាខ័ណ្ឌ១ នៃមាត្រានេះ កិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តដូចដែលបានកែសម្រួលតាមវិធានការនានាដែលបានអនុម័តនៅក្រោមមាត្រា ២២ នៃ ACIA (ការចូលមកការធ្វើការងាររបស់អ្នកវិនិយោគ និងការស្នាក់នៅបណ្តោះអាសន្ន និងបុគ្គលសំខាន់ៗ) សម្រាប់បំលាស់ទីរូបវន្តបុគ្គលនៃរដ្ឋជាសមាជិក នៅក្នុងទឹកដីរបស់រដ្ឋជាសមាជិកណាមួយផ្សេងទៀត។

៣. ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ ផ្នែកB (វិវាទវិនិយោគរវាងអ្នកវិនិយោគណាមួយជាមួយនឹងរដ្ឋជាសមាជិកណាមួយ) នៃ ACIA នឹងមិនត្រូវយកមកអនុវត្តនៅក្នុងកិច្ចព្រមព្រៀងនេះទេ។

## មាត្រា១៣
## ការទទួលស្គាល់

១. សម្រាប់គោលបំណងទាំងឡាយនៃការអនុវត្តន៍ទាំងស្រុង ឬដោយផ្អែកលើបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យ សម្រាប់ការអនុញ្ញាតិផ្តល់អាជ្ញាប័ណ្ណ ឬចេញវិញ្ញាបនប័ត្រដល់អ្នកផ្គត់ផ្គង់សេវា និងជាកម្មវត្ថុនៃសេចក្តីតម្រូវនៃកថាខ័ណ្ឌ៣ នៃមាត្រានេះ, រដ្ឋសមាជិកមួយ តាមការព្រមព្រៀង ឬការរៀបចំជាមួយរដ្ឋជាសមាជិកផ្សេងទៀត អាចទទួលស្គាល់ការអប់រំ ឬបទពិសោធន៍ការងារ, បំពេញបានតាមសេចក្តីតម្រូវឬ

អាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្របញ្ជាក់ ដែលបានផ្តល់ឱ្យនៅក្នុងប្រទេសសមាជិកផ្សេងទៀត។

២. នៅពេលរដ្ឋជាសមាជិកមួយទទួលស្គាល់ ដោយការព្រមព្រៀង ឬយល់ព្រមគ្នាជាមួយនឹងរដ្ឋមិនមែនជាសមាជិក ឬជាឯកតោភាគីជាមួយនឹងរដ្ឋជាសមាជិកដទៃទៀត ឬរដ្ឋមិនមែនជាសមាជិកណាមួយ រដ្ឋសមាជិកនេះត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់សមាជិកផ្សេងទៀត ដើម្បីបង្ហាញថាការអប់រំ បទពិសោធន៍ អាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រដែលទទួលបាន ឬការបំពេញបានតាមសេចក្តីតម្រូវនៅក្នុងប្រទេសសមាជិកដទៃទៀត ក៏ត្រូវតែទទួលបាននូវការទទួលស្គាល់ផងដែរ។

៣. ប្រទេសសមាជិក មិនត្រូវផ្តល់ការទទួលស្គាល់ក្នុងលក្ខណៈមួយ ដែលបង្កើតមធ្យោបាយឱ្យមានការរើសអើង ប្រឆាំងនិងរដ្ឋជាសមាជិកមួយផ្សេងទៀតនៅក្នុងការអនុវត្តន៍បទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ការអនុញ្ញាត ការផ្តល់អាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រដល់អ្នកផ្គត់ផ្គង់សេវា ឬធ្វើការរឹតត្បិតដោយប្រើប្រាស់មូលហេតុក្លែងក្លាយលើពាណិជ្ជកម្មសេវាកម្មឡើយ។ នៅពេលសមស្របណាមួយ ការទទួលស្គាល់ ត្រូវឈរលើលក្ខណៈវិនិច្ឆ័យនៃការព្រមព្រៀងពហុភាគី។

៤. រដ្ឋជាសមាជិកនីមួយៗ ត្រូវជម្រុញលើកទឹកចិត្តស្ថាប័នមានសមត្ថកិច្ចនានា នៅក្នុងទឹកដីរបស់ខ្លួន ចូលទៅធ្វើកិច្ចសហប្រតិបត្តិការព្រមព្រៀង ឬយល់ព្រមជាពហុភាគី ឬទ្វេភាគី ទៅលើការទទួលស្គាល់វិជ្ជាជីវៈ ដូចជា៖

(ក) តម្រូវការលើសមត្ថភាព

(ខ) នីតិវិធីសម្រាប់កំណត់លើសមត្ថភាព

(គ) អាជ្ញាប័ណ្ណ, វិញ្ញាបនប័ត្រ ឬ សេចក្តីត្រូវការចុះបញ្ជី និងនីតិវិធីផ្សេងៗ

## មាត្រា១៤
## យន្តការស្ថាប័ន

១. រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ត្រូវទទួលខុសត្រូវលើការអនុវត្តកិច្ចព្រមព្រៀងនេះ ។

២. រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ត្រូវសម្របសម្រួល និងទទួលខុសត្រូវអនុវត្តកិច្ចព្រមព្រៀងនេះជាមួយនឹងប្រទេសជាសមាជិក និងស្ថាប័នពាក់ព័ន្ធរបស់អាស៊ាននានា ។

៣. សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ គណៈកម្មាធិការសម្របសម្រួលការងារសេវាកម្មអាស៊ាន(CCS) និងមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធនានា ត្រូវជួយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ។

៤. នៅក្នុងការបំពេញឱ្យបាននូវភារកិច្ចនេះ, រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន អាចនឹងបង្កើតនូវស្ថាប័នជំនួយ និងតែងតាំងស្ថាបន័នានា ដើម្បីរៀបចំនិងបំពេញការងារច្បាស់លាស់ ឬប្រគល់សិទ្ធិទទួលខុសត្រូវឱ្យទៅស្ថាប័នជំនួយនានា នោះ។

## មាត្រា១៥
## ការពិនិត្យឡើងវិញ, ការកែសម្រួល និងការធ្វើវិសោធនកម្ម

១. រដ្ឋជាសមាជិកនីមួយៗ អាចនឹងស្នើធ្វើការពិនិត្យឡើងវិញ, ការកែសម្រួល ឬការធ្វើវិសោធនកម្មទាំងស្រុង ឬក្នុងផ្នែកណាមួយរបស់កិច្ចព្រមព្រៀងនេះ ដោយសរសេរជាលាយលក្ខណ៍អក្សរ។
២. បទបញ្ញត្តិនានារបស់កិច្ចព្រមព្រៀងនេះ អាចនឹងកែសម្រួល ឬធ្វើវិសោធនកម្មបាន លុះត្រាតែមានការព្រមព្រៀងគ្នាទៅវិញទៅមក ដោយសរសេរជាលាយលក្ខណ៍អក្សរពីរដ្ឋាភិបាលរបស់ប្រទេសជាសមាជិកទាំងអស់។
៣. ការពិនិត្យឡើងវិញ ការកែសម្រួល ឬការធ្វើវិសោធនកម្មនានា ត្រូវធ្វើឡើងតាមផ្នែកណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ដោយមានការឯកភាពគ្នាជាលាយលក្ខណ៍អក្សរ។
៤. ការពិនិត្យឡើងវិញ, ការកែសម្រួល ឬការធ្វើវិសោធនកម្ម និងត្រូវចូលជាធរមានទៅតាមកាលបរិច្ឆេទដែលសម្រេច ដោយរដ្ឋជាសមាជិកទាំងអស់។
៥. ការពិនិត្យឡើងវិញ, ការកែសម្រួល ឬការធ្វើវិសោធនកម្មនានា នឹងមិនត្រូវធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចនានា ដែលកើតមានឡើងចាប់ពីការព្រមព្រៀងគ្នាលើកដំបូង ឬក៏រហូតដល់ពេលដែលធ្វើការពិនិត្យឡើងវិញ, ការកែសម្រួល ឬការធ្វើវិសោធនកម្ម។

## មាត្រា១៦
## ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានក្រោយពីរដ្ឋជាសមាជិកទាំងអស់ បានធ្វើសេចក្តីជូនដំណឹង ឬនៅពេលណាចាំបាច់ ត្រូវតំកល់ទុកឯកសារផ្តល់សច្ចាប័ននៅលេខាធិការដ្ឋានអាស៊ាន ដោយមិនឱ្យលើសពី ១៨០ ថ្ងៃ បន្ទាប់ពីកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខា។

២. លេខាធិការដ្ឋានអាស៊ាន ត្រូវធ្វើការជូនដំណឹងដល់រដ្ឋជាសមាជិកទាំងអស់ភ្លាមៗ ឬត្រូវតំកល់ទុកនូវរាល់លិខិតតុបករណ៍ដែលផ្តល់សច្ចាប័ន ដោយអនុលោមទៅតាមកថាខណ្ឌ១ នៃមាត្រានេះ។

**មាត្រា១៧**
**ការតំកល់ទុក**

កិច្ចព្រមព្រៀងនេះ ត្រូវតំកល់ទុកនៅលេខាធិការដ្ឋានអាស៊ាន ហើយលេខាធិការដ្ឋានអាស៊ានត្រូវផ្តល់នូវឯកសារ បញ្ជាក់ថតចំលងជូនទៅរដ្ឋជាសមាជិកនីមួយៗ។

**ដើម្បីជាសាក្សីច្បាប់** ហត្ថលេខាខាងក្រោម ត្រូវបានប្រគល់សិទ្ធិតាមផ្លូវច្បាប់ដោយរដ្ឋាភិបាលនៃរដ្ឋជាសមាជិកនីមួយៗ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអាស៊ានស្តីពីបំលាស់ទីរូបវន្តបុគ្គល ។

ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ ២០១២ ចំនួនមួយច្បាប់ជាភាសាអង់គ្លេស។

តំណាងរដ្ឋាភិបាលប្រ៊ុយណេដារុយសាឡាំ
រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូនេស៊ី
រដ្ឋមន្ត្រីពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
រដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលម៉ាឡេស៊ី
រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្មអន្តរជាតិ

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធមីយ៉ាន់ម៉ា
រដ្ឋមន្ត្រីផែនការជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច

តំណាងរដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន
លេខាធិការពាណិជ្ជកម្ម និងឧស្សាហកម្ម

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសឹង្ហបុរី
រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

តំណាងរដ្ឋាភិបាលព្រះរាជាណាចក្រថៃ
រដ្ឋមន្ត្រីពាណិជ្ជកម្ម

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម
រដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្ម

**បកប្រែក្រៅផ្លូវការ**

# កិច្ចព្រមព្រៀងអាស៊ានស្តីពីចំលាស់ទីរូបវន្តបុគ្គល

## តារាងនៃការសន្យារបស់ប្រទេសកម្ពុជាសម្រាប់ការចូលមក របស់រូបវន្តបុគ្គល

១. តារាងនៃការសន្យារបស់ប្រទេសកម្ពុជា នៃមាត្រា៤ ដែលទាក់ទងនឹង ផ្តល់ការអនុញ្ញាតឱ្យចូលមកបណ្តោះអាសន្ន ឬការស្នាក់នៅបណ្តោះអាសន្ន ចំពោះរូបវន្តបុគ្គលរបស់រដ្ឋជាសមាជិកដទៃទៀត អនុវត្តតែចំពោះក្រុម រូបវន្តបុគ្គលដែលបានកំណត់ដូចខាងក្រោមតែប៉ុណ្ណោះ។

២. យោងមាត្រា៦ សម្រាប់ក្រុមរូបវន្តបុគ្គលដែលបានកំណត់ក្នុង តារាងនៃការសន្យាប្រទេសកម្ពុជាកំណត់នូវនិយមន័យ លក្ខខណ្ឌ ដែនកំណត់ ឬគុណវុឌ្ឍិនានា ដែលទាក់ទងនឹងការចូលមកបណ្តោះអាសន្ន និងការស្នាក់នៅបណ្តោះអាសន្ន ចំពោះរូបវន្តបុគ្គលអាស៊ានម្នាក់នៅក្នុងដែនដីរបស់ខ្លួន។

| ការចូលមក តែប្រភេទដូចខាងក្រោមប៉ុណ្ណោះ | លក្ខខណ្ឌ (រួមទាំងរយៈពេលនៃការស្នាក់នៅ) |
|---|---|
| **<u>អ្នកធ្វើទស្សនៈកិច្ចជំនួញ៖</u>**<br>**<u>និយមន័យ:</u>** រូបវន្តបុគ្គលដែល៖<br>- ចូលមកប្រទេសកម្ពុជា ក្នុងគោលបំណងចូលរួមកិច្ចប្រជុំជំនួញ បង្កើតទំនាក់ទំនងជំនួញ រួមទាំងការចរចារក្នុងការលក់ សេវាកម្មនឹង/ឬធ្វើសកម្មភាពប្រហាក់ប្រហែល ដទៃទៀត;<br>- ស្នាក់នៅប្រទេសកម្ពុជា ដោយមិនទទួលប្រាក់ចំណូលពីប្រភពក្នុងប្រទេសកម្ពុជាឡើយ<br>- មិនពាក់ព័ន្ធនឹងការលក់ទំនិញ ឬការផ្គត់ផ្គង់សេវាដោយផ្ទាល់ ទៅឱ្យសាធារណជនទេ | ទិដ្ឋាការសម្រាប់អ្នកចូលមកធ្វើទស្សនៈកិច្ចក្នុងបំណងដើម្បីធ្វើពាណិជ្ជកម្មមានសុពលភាពចំនួន ៩០ថ្ងៃ សម្រាប់ការចូលមកស្នាក់នៅដំបូងចំនួន ៣០ថ្ងៃ រួចអាចធ្វើការពន្យាពេលបាន |
| **<u>អ្នកដែលទទួលខុសត្រូវក្នុងការរៀបចំបង្កើត សហគ្រាស គ្រឹះស្ថាន ពាណិជ្ជកម្ម</u>**<br>**<u>និយមន័យ:</u>** អ្នកដែលធ្វើការក្នុងតំណែងជាន់ខ្ពស់ ឬ អ្នកគ្រប់គ្រងដែលបានប្រាក់ខែពីក្រុមហ៊ុន ដូចមានចែងក្នុងនិយមន័យខាងក្រោម ហើយជាអ្នកទទួលខុសត្រូវក្នុង | បុគ្គលិកទាំងនេះ មិនស្នាក់នៅរហូតដល់រយៈពេលអតិបរមាទេ។ |

| | |
|---|---|
| ការរៀបចំបង្កើតនៅប្រទេសកម្ពុជានូវក្រុមហ៊ុនផ្តល់សេវានៃប្រទេសសមាជិកមួយ ហើយទ្រទ្រង់ដល់មុខរបររបស់បុគ្គលដែលបានរៀបរាប់នៅក្នុងប្រភេទ(ក) (ខ) និង(គ) នៃបុគ្គលិកផ្ទេរនៃក្រុមហ៊ុន។ | |
| **<u>បុគ្គលិកផ្ទេរនៃក្រុមហ៊ុន</u>**<br><br>**<u>និយមន័យ:</u>** រូបវន្តបុគ្គល ដែលត្រូវបានជ្រើសរើសយកមកធ្វើការដោយនីតិបុគ្គលនៃសមាជិកផ្សេងទៀតក្នុងរយៈពេលមិនតិចជាង ១ឆ្នាំ និងអ្នកដែលចង់ចូលមកស្នាក់នៅជាបណ្តោះអាសន្ន ដើម្បីផ្តល់សេវាតាមរយៈសាខាក្រុមហ៊ុន តំណាងក្រុមហ៊ុន និងសាខាតំណាងក្រុមហ៊ុននៅកម្ពុជា និងបុគ្គល ដែលជាៈ<br><br>**<u>ក. នាយកប្រតិបត្តិ (Executive):</u>** ដោយមិនតម្រូវឱ្យអនុលោមតាមតេស្តទីផ្សារការងារ, បុគ្គលដែលធ្វើការក្នុងក្រុមហ៊ុនមួយ ហើយដឹកនាំ គ្រប់គ្រងដោយផ្ទាល់ មានអំណាចក្នុងធ្វើសេចក្តី សម្រេចចិត្តធំទូលាយ និងទទួលការត្រួតពិនិត្យទូទៅ ឬដោយផ្ទាល់ពីថ្នាក់ប្រតិបត្តិខ្ពស់ជាង ពីក្រុមប្រឹក្សានាយក ឬសមាជិកភាគហ៊ុននៃក្រុមហ៊ុន។ នាយកប្រតិបត្តិ នឹងមិនត្រូវអនុវត្តការងារផ្ទាល់នានាដែលទាក់ទិននឹងការផ្តល់សេវា ជាក់ស្តែង ឬសេវាក្រុមហ៊ុនឡើយ។<br><br>**<u>ខ. អ្នកគ្រប់គ្រង (Manager):</u>**<br>ដោយមិនតម្រូវឱ្យអនុលោមតាមតេស្តទីផ្សារការងារ, រូបវន្តបុគ្គលដែលជួលដោយនីតិបុគ្គល និងអ្នកមានជំនាញខ្ពស់ ឬមានចំណេះដឹងសមស្របពាក់ព័ន្ធនឹងផលិតផល សេវាកម្ម ការស្រាវជ្រាវ សម្ភារ បច្ចេកទេស ឬការគ្រប់គ្រងរបស់នីតិបុគ្គល និងអ្នកដែលដឹកនាំផ្ទាល់នៃក្រុមហ៊ុន ឬនាយកដ្ឋាននានានៃក្រុមហ៊ុន។ ធ្វើការត្រួតពិនិត្យ និងគ្រប់គ្រងកិច្ចការរបស់អ្នកត្រួតពិនិត្យបុគ្គលិកអាជីព ឬបុគ្គលិកផ្នែកគ្រប់គ្រង ដទៃទៀត ហើយមានអំណាចក្នុងការជួល ឬដេញចោល ឬផ្តល់អនុសាសន៍ក្នុងការជួល ឬដេញចោល ឬការងារបុគ្គលិកដទៃទៀត និងអនុវត្តនូវអំណាចឆន្ទានុសិទ្ធិក្នុងប្រតិបត្តិការប្រចាំថ្ងៃ។ ពួកគេទាំងនោះ មិនរាប់បញ្ចូល | រូបវន្តបុគ្គល ដែលជាបុគ្គលិកផ្ទេរនៃក្រុមហ៊ុន តម្រូវឱ្យមានការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្ន និងធ្វើការងារ។ ការអនុញ្ញាតទាំងនោះមានសុពលភាពរយៈពេល ២ឆ្នាំ ហើយអាចធ្វើឡើងវិញជារៀងរាល់ឆ្នាំ រហូតដល់រយៈពេលយូរបំផុត ៥ឆ្នាំ។ |

| | |
|---|---|
| អ្នកគ្រប់គ្រងថ្នាក់ទី១ទេ លុះត្រាតែ បុគ្គលដែលត្រូវគេគ្រប់គ្រងនោះ ជាបុគ្គលិកអាជីព ហើយមិនរាប់បញ្ចូលផងដែរនូវបុគ្គលិកដែលបំពេញកិច្ចការចាំបាច់នានាសម្រាប់ការងារផ្គត់ផ្គង់សេវានោះទេ។<br>**គ. អ្នកឯកទេស (Specialist):** រូបវន្តបុគ្គល នៅក្នុងក្រុមហ៊ុនមួយដែលមានកំរិតចំណេះជំនាញខ្ពស់ជាបន្ត និងអ្នកដែលមានចំណេះសមស្របស្តីពីសេវា ការងារស្រាវជ្រាវ សម្ភារ បច្ចេកទេស ឬការងារគ្រប់គ្រងរបស់ក្រុមហ៊ុន។ | |
| **អ្នកផ្តល់សេវា ដែលមានកិច្ចសន្យា(Contractual Service Suppliers):**<br>អ្នកផ្គត់ផ្គង់សេវា ដែលមានកិច្ចសន្យា គឺរូបវន្តបុគ្គលដែលជួលដោយនីតិបុគ្គល បង្កើតក្នុងប្រទេសសមាជិកដែលមិនមានវត្តមានពាណិជ្ជកម្មនៅក្នុងប្រទេសជាសមាជិកផ្សេងទៀត ជាបុគ្គលះ<br>១-ចូលក្នុងប្រទេសសមាជិកនោះ ដើម្បីផ្គត់ផ្គង់សេវាកម្មស្របតាមកិច្ចសន្យារវាងនិយោជករបស់ខ្លួន នឹងអ្នកប្រើប្រាស់សេវាកម្មនៅក្នុងប្រទេសសមាជិកដទៃទៀត<br>២-អាចជានាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬអ្នកឯកទេសដូចមានចែងក្នុងអនុកថាខណ្ឌ(ក), (ខ) និង (គ) នៃមាត្រានេះ ដែលទទួលប្រាក់ឈ្នួលពីនិយោជករបស់ខ្លួន<br>៣-ត្រូវមានចំណេះដឹង និងជំនាញសមស្របដែលពាក់ព័ន្ធនឹងសេវាកម្ម ដែលបានផ្តល់ និង<br>៤-អាចជាបុគ្គលិករបស់នីតិបុគ្គលសម្រាប់រយៈពេលដូចមានក្នុងតារាងនៃការសន្យា | រូបវន្តបុគ្គល ដែលជាអ្នកផ្តល់សេវាដែលមានកិច្ចសន្យា តម្រូវឱ្យមានការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្ន និងធ្វើការងារ។ ការអនុញ្ញាតទាំងនោះមានសុពលភាពរយៈពេល ២ឆ្នាំ ហើយអាចធ្វើឡើងវិញជារៀងរាល់ឆ្នាំ រហូតដល់រយៈពេលយូរបំផុត ៥ឆ្នាំ។ |

៣. ការសន្យាដែលកំណត់ខាងលើ អនុវត្តសម្រាប់ផ្នែក/អនុផ្នែកសេវាដូចមានបញ្ជាក់នៅក្នុងតារាងនៃការសន្យារបស់ប្រទេសកម្ពុជា ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីសេវាកម្ម (AFAS) លើកលែងថាភោជនីយដ្ឋាន (CPC 642, 643)

៤. ប្រទេសកម្ពុជានៅតែមិនជាប់កាតព្វកិច្ចលើការកំណត់ប្រព្រឹត្តិកម្មជាតិ (National Treatment Limitations) ដែលអាចអនុវត្តបានចំពោះការទំនុកបម្រុងជាសាច់ប្រាក់ រួមទាំងសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍ។

៥. រាល់ការសន្យា ក្នុងបរិបទនៃវត្តមានរបស់រូបវន្តបុគ្គលនៅក្នុងតារាងនៃកាសន្យាជាក់លាក់របស់ប្រទេសកម្ពុជា ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីសេវាកម្មរួមមានការសន្យាផ្សេងៗ បទបញ្ជានានានិងការសន្យាបន្ថែមផ្សេងទៀត អនុវត្តចំពោះអ្នកផ្តល់សេវាកម្មនៃប្រទេសសមាជិកអាស៊ានដទៃទៀត។

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

រាជរដ្ឋាភិបាល
*Royal Government*

No. 109 . D-F.P

*Phnom Penh, October 22 ,2012*

## DELEGATION OF FULL POWERS

- Considering the Constitution of the Kingdom of Cambodia,
- Considering the Royal Decree NS/RKT/0908/1055 dated 25 September 2008 on the Nomination of the Royal Government of Cambodia,
- Considering the Royal Kram 02/NS/94 dated 20 July 1994 promulgating the Law on the Organization and Functioning of the Council of Ministers,
- Considering the Royal Kram NS/RKM/0196/16 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Commerce,
- Pursuant to the Proposal of the Minister of Commerce.

## THE ROYAL GOVERNMENT

Delegates herewith Full Powers to His Excellency Dr. **CHAM PRASIDH**, Senior Minister, Minister of Commerce and ASEAN Economic Minister for Cambodia to sign the **ASEAN Agreement on Movement of Natural Person**.

This power includes the power of delegation.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed the Delegation of Full Powers.

Prime Minister

Samdech Akka Moha Sena Padei Techo **HUN SEN**

# ASEAN AGREEMENT ON THE MOVEMENT OF NATURAL PERSONS

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, Member States of the Association of South East Asian Nations ("ASEAN"), hereinafter collectively referred to as "Member States" or singularly as "Member State";

**NOTING** the mandate of the ASEAN Economic Community Blueprint adopted at the 13th ASEAN Summit held on 20 November 2007 in Singapore that free flow of skilled labour is one of the core elements of an ASEAN single market and production base, which allows for managed mobility or facilitated entry for the movement of natural persons engaged in trade in goods, trade in services and investment, according to the prevailing regulations of the receiving country;

៩- នាយចំណង់ ស៊ិន ឧទ្ធរ អត្តលេខ ១៣៨០៣៨ ជំនួយការវិស្វកម្ម វរសេនាតូចលេខ១១២ កងពលតូចអន្តរាគមន៍លេខ១១

| | | | | | | |
|---|---|---|---|---|---|---|
| ១០- | នាយចំណង់ | អ៊ុយ | ប្រុស | អត្តលេខ | ០៦៥៨៧១ | ជំនួយការបញ្ជូនសារ វរសេនាតូចលេខ១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ១១- | នាយចំណង់ | ទណ្ឌ | ណា | អត្តលេខ | ១៩០១២៧ | មេ.ការរង អ.តូចស៊ើបការណ៍ការពារ វរសេនាតូចលេខ១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ១២- | នាយចំណង់ | កែវ | សារិទ្ធ | អត្តលេខ | ១៧៨៧០៤ | មេ.ការរងអ.តូច៣ អ.ធំ១ វរសេនាតូចលេខ១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៣- | នាយចំណង់ | ឡើក | ខ្លា | អត្តលេខ | ១៥៨៨១៨ | ជំនួយការពេទ្យ វរសេនាតូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៤- | នាយចំណង់ | ស៊ុន | ម៉ុនថៃ | អត្តលេខ | ០៩៥៥៣៤ | ជំនួយការប្រតិបត្តិការសឹក វរសេនាតូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៥- | នាយចំណង់ | យុត | សារ៉ាត់ | អត្តលេខ | ០៨៩៦០៤ | មេបញ្ជាការរង អ.ធំ១ វរសេនាតូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៦- | នាយចំណង់ | អ៊ុត | ផល្លា | អត្តលេខ | ១៣៧២៥៣ | មេ.ការរង អ.ធំ៣ វរសេនាតូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៧- | នាយចំណង់ | ទូច | ទណ្ឌ | អត្តលេខ | ០៩៥៧១៩ | មេបញ្ជាការរង អ.តូចកាំភ្លើងធំ អ.ធំគាំទ្រ វរសេនាតូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៨- | នាយចំណង់ | ឡេង | ឈុនលី | អត្តលេខ | ១៤២៧៦៥ | មេបញ្ជាការរង អ.ធំទី៣ វរសេនាតូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៩- | នាយចំណង់ | ញឿង | ឥន្ទី | អត្តលេខ | ១៣៧៧០២ | មេបញ្ជាការរង អ.តូច១ អ.ធំស៊ើបការណ៍ កងពលតូចអន្តរាគមន៍លេខ១១ |
| ២០- | ព្រិន្ទបាលឯក | ឃួន | ខុន | អត្តលេខ | ២០៩៤៦៥ | ជំនួយការការិយាល័យអភិវឌ្ឍន៍ កងពលតូចអន្តរាគមន៍លេខ១១ |
| ២១- | ព្រិន្ទបាលឯក | សឿន | សុញ៉ា | អត្តលេខ | ១៦៧៧២៨ | មេបញ្ជាការរង អ.តូច២ អ.ធំ១ វរសេនាតូចលេខ១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ២២- | ព្រិន្ទបាលឯក | ឌុល | ឌុច | អត្តលេខ | ១៧៨៧២៤ | នាយក្រុមអ.តូចត្បាល់៨២ អ.ធំគាំទ្រ វ.តូច១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៣- | ព្រិន្ទបាលឯក | យន | សុមុន | អត្តលេខ | ១៧៨៧៤៦ | បុគ្គលិករដ្ឋបាល វរសេនាតូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៤- | ព្រិន្ទបាលឯក | ហែម | សំអាន | អត្តលេខ | ១៩០៧៥២ | នាយក្រុមអ.តូច២ អ.ធំ១ វ.តូច១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៥- | ព្រិន្ទបាលឯក | សែម | សាន | អត្តលេខ | ១៤០៧៨៩ | បុគ្គលិកបំរើការ អ.ធំ១ វ.តូច១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៦- | ព្រិន្ទបាលឯក | មឿយ | កេត | អត្តលេខ | ១៥១៩៣៥ | មេបញ្ជាការរង អ.តស៊ើបការណ៍ការពារ វ.តូច១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៧- | ព្រិន្ទបាលឯក | ម៉ុច | ម៉ៃ | អត្តលេខ | ១៩០៥៥២ | នាយពួក អ.តស៊ើបការណ៍ការពារ វ.តូច១១៣ កងពលតូចអន្តរាគមន៍លេខ១១ |

## គ-មេដាយសំរឹទ្ធការងារ

| | | | | | | |
|---|---|---|---|---|---|---|
| ១- | វរសេនីយ៍ត្រី | មាស | សឿន | អត្តលេខ | ០២៦៧៧០ | នាយឯកទេសគីមីសាស្ត្រ កងពលតូចអន្តរាគមន៍លេខ១១ |
| ២- | អនុសេនីយ៍ទោ | ផាត | ផានិត | អត្តលេខ | ០៥៨៧០១ | ជំនួយការ ការិយាល័យទី៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ៣- | អនុសេនីយ៍ទោ | ឈុន | សុវណ្ណារិទ្ធ | អត្តលេខ | ១៥៨៧៧៦ | មេបញ្ជាការរង អ.ធំ២ វ.តូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤- | អនុសេនីយ៍ត្រី | មួន | ម៉ី | អត្តលេខ | ១៥៨៨៩៥ | មេបញ្ជាការ អ.តូច២ អ.ធំ៣ វ.តូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ៥- | នាយចំណង់ | សែម | ចំរើន | អត្តលេខ | ១៣៧៧០៩ | ជំនួយការលេខាធិការដ្ឋាន កងពលតូចអន្តរាគមន៍លេខ១១ |
| ៦- | នាយចំណង់ | សំ | ផានី | អត្តលេខ | ១៣៧៧០៨ | ជំនួយការលេខាធិការដ្ឋាន កងពលតូចអន្តរាគមន៍លេខ១១ |
| ៧- | នាយចំណង់ | ព្រហ្ម | សម្បត្តិ | អត្តលេខ | ០៨០០៥៤ | មេ.ការរង អ.តូច៣ អ.ធំស៊ើបការណ៍ កងពលតូចអន្តរាគមន៍លេខ១១ |
| ៨- | នាយចំណង់ | អន | ចន្ថា | អត្តលេខ | ១១៥៥៦០ | មេ.ការរង អ.តូច២ អ.ធំស៊ើបការណ៍ កងពលតូចអន្តរាគមន៍លេខ១១ |
| ៩- | នាយចំណង់ | ឈុក | ណារាន | អត្តលេខ | ១៤២៧១៨ | មេ.ការ អ.តូច៣ អ.ធំស្ពានថ្នល់ កងពលតូចអន្តរាគមន៍លេខ១១ |
| ១០- | នាយចំណង់ | ទ្រី | សុខុំ | អត្តលេខ | ១៤៦១១៦ | ជំនួយការការិយាល័យសុខាភិបាល កងពលតូចអន្តរាគមន៍លេខ១១ |
| ១១- | នាយចំណង់ | និត្យ | សុធី | អត្តលេខ | ២១៧២៧៧ | មេ.ការ អ.តូច១ អ.ធំ២ វ.តូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ១២- | នាយចំណង់ | លន | សុខ | អត្តលេខ | ០៩៥៤៩៦ | មេ.ការ អ.តូច១ អ.ធំ១ វ.តូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៣- | នាយចំណង់ | ពុធ | អនុរក្ស | អត្តលេខ | ១៣៧៨៣៣ | ជំនួយការ ការិយាល័យទី១ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៤- | នាយចំណង់ | សំរិត | រ៉េត | អត្តលេខ | ១៧៨៧៤៩ | មេ.ការ អ.តូច២ អ.ធំ២ វ.តូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៥- | នាយចំណង់ | គីម | ណារ៉ាង | អត្តលេខ | ១៧៨៧២៣ | មេ.ការរង អ.តូច១ អ.ធំ៣ វ.តូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៦- | នាយចំណង់ | គួ | មិត | អត្តលេខ | ១៧៨៦៩១ | មេ.ការរង អ.តូច២ អ.ធំ១ វ.តូចលេខ១១១ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៧- | នាយចំណង់ | មេត | ជឿន | អត្តលេខ | ០៩៥០៦២ | ជំនួយការពេទ្យ វ.តូចលេខ១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៨- | ព្រិន្ទបាលឯក | ហ៊ិន | ចាន់ថុល | អត្តលេខ | ១៣៧៩៥៥ | នាយក្រុម អ.តូចត្បាល់៨២មម អ.ធំគាំទ្រ វ.តូចលេខ១១១ កងពលតូចអន្តរាគមន៍លេខ១១ |
| ១៩- | ព្រិន្ទបាលឯក | ស៊ិន | ចន្ធា | អត្តលេខ | ១៣៧៩៧២ | បុគ្គលិកពេទ្យ អ.ធំ១ វ.តូចលេខ១១១ កងពលតូចអន្តរាគមន៍លេខ១១ |
| ២០- | ព្រិន្ទបាលឯក | សន | សុផា | អត្តលេខ | ១៣៧៩៥៦ | នាយក្រុម អ.តូច១ អ.ធំ១ វ.តូចលេខ១១១ កងពលតូចអន្តរាគមន៍លេខ១១ |
| ២១- | ព្រិន្ទបាលឯក | សោម | សុផល | អត្តលេខ | ១៤០៨៤៥ | នាយក្រុម អ.តូច៣ អ.ធំ២ វ.តូចលេខ១១១ កងពលតូចអន្តរាគមន៍លេខ១១ |

| | | | | | | |
|---|---|---|---|---|---|---|
| ២២- | ព្រិន្ទបាលឯក | មាស | សាខ៊ុន | អត្តលេខ | ២០៩៥២៧ | មេបញ្ជាការរង អ.តូច៣ អ.ធំ៣ វ.តូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៣- | ព្រិន្ទបាលឯក | ស៊ឹប | ហេន | អត្តលេខ | ០៩០១១៩ | មេបញ្ជាការរង អ.តូចស៊ើបការណ៍ការពារ វ.តូចលេខ១១៤ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៤- | ព្រិន្ទបាលឯក | ម៉ែន | សុខុម | អត្តលេខ | ១៩០៦៥៩ | មេបញ្ជាការ អ.តូចកាំភ្លើងយន្ត អ.ធំគាំទ្រ វ.តូចលេខ១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៥- | ព្រិន្ទបាលឯក | សែម | មូណារ៉ា | អត្តលេខ | ១៧៨៧០០ | នាយក្រុម អ.តូចកាំភ្លើងយន្ត អ.ធំគាំទ្រ វ.តូចលេខ១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៦- | ព្រិន្ទបាលឯក | ហ៊ត | មីន | អត្តលេខ | ១៤០៧៦៧ | បុគ្គលិកបំរើការ អ.ធំ១ វ.តូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១ |
| ២៧- | ព្រិន្ទបាលឯក | ចាន់ | សាន | អត្តលេខ | ១៨៦៨២៨ | បុគ្គលិកបំរើការ អ.ធំ១ វ.តូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១ |
| ២៨- | ព្រិន្ទបាលឯក | ឈុម | គន | អត្តលេខ | ១៨៦៨២៩ | នាយក្រុម អ.តូច១ អ.ធំ២ វ.តូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ២៩- | ព្រិន្ទបាលឯក | ហ៊ិន | ម៉ៅ | អត្តលេខ | ០៨៣៣៨១ | បុគ្គលិកបំរើការ អ.ធំគាំទ្រ វ.តូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ៣០- | ព្រិន្ទបាលឯក | ម៉ម | រឿប | អត្តលេខ | ១៩០៧២៣ | នាយក្រុមរង អ.តូចស៊ើបការណ៍ការពារ វ.តូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ៣១- | ព្រិន្ទបាលឯក | ហែម | ស្លា | អត្តលេខ | ១៣៧៧១៩ | បុគ្គលិកបំរើការ វ.តូចលេខ១១៣ កងពលតូចអន្តរាគមន៍លេខ១១ |
| ៣២- | ព្រិន្ទបាលឯក | រ៉ែន | ម៉េត | អត្តលេខ | ២២៨៥៤៦ | នាយក្រុម អ.ធំដឹកជញ្ជូន កងពលតូចអន្តរាគមន៍លេខ១១ |
| ៣៣- | ព្រិន្ទបាលឯក | ឌូ | ចាន់តារៈ | អត្តលេខ | ១៦៨៩០៩ | នាយក្រុម អ.ធំដឹកជញ្ជូន កងពលតូចអន្តរាគមន៍លេខ១១ |
| ៣៤- | ព្រិន្ទបាលឯក | យស | គា | អត្តលេខ | ១៤៦៦៥៩ | នាយក្រុម អ.ធំការពារ កងពលតូចអន្តរាគមន៍លេខ១១ |
| ៣៥- | ព្រិន្ទបាលឯក | យូ | សៅរិទ្ធ | អត្តលេខ | ០៦០០៩៣ | មេ.ការ អ.តូច២ អ.ធំស៊ើបការណ៍ កងពលតូចអន្តរាគមន៍លេខ១១ |
| ៣៦- | ព្រិន្ទបាលឯក | អោម | ញ៉ិល | អត្តលេខ | ១៥៨៩៩៧ | នាយក្រុម អ.តូច២ អ.ធំស៊ើបការណ៍ កងពលតូចអន្តរាគមន៍លេខ១១ |
| ៣៧- | ព្រិន្ទបាលឯក | អ៊ុំ | ត្រីម៉ា | អត្តលេខ | ០៧៧១៥៦ | បុគ្គលិកពេទ្យសង្គ្រោះ អ.ធំការពារអាកាស កងពលតូចអន្តរាគមន៍លេខ១១ |
| ៣៨- | ព្រិន្ទបាលឯក | ខែត | សុខុន | អត្តលេខ | ១៥១៧៥៣ | នាយក្រុម អ.តូច៣ អ.ធំការពារអាកាស កងពលតូចអន្តរាគមន៍លេខ១១ |
| ៣៩- | ព្រិន្ទបាលឯក | ឌឹម | ទី | អត្តលេខ | ១៣៧៨៣៤ | មេបញ្ជាការរង អ.តូច២ អ.ធំបញ្ជូនសារ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤០- | ព្រិន្ទបាលឯក | ខាន់ | រីន | អត្តលេខ | ១៤០៨៣៦ | នាយក្រុម អ.តូច២ អ.ធំបញ្ជូនសារ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤១- | ព្រិន្ទបាលឯក | គង់ | ចន្ថា | អត្តលេខ | ១៨៦៩១៥ | បុគ្គលិកបំរើការ គិលានដ្ឋាន កងពលតូចអន្តរាគមន៍លេខ១១ |

| | | | | | | |
|---|---|---|---|---|---|---|
| ៤២- | ព្រិន្ទបាលទោ | ហាឡ | ម៉ុនថាច | អត្តលេខ | ១៣៧៩៨០ | នាយក្រុមរង អ.តូច៣ អ.ធំ៣ វ.តូច១១១ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤៣- | ព្រិន្ទបាលទោ | អ៊ិន | ពៅ | អត្តលេខ | ១៣៨០១៤ | នាយក្រុម អ.តូចស៊ើបការណ៍ការពារ វរសេនាតូច១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤៤- | ព្រិន្ទបាលទោ | ហ៊ើ | ឧុទ្ធី | អត្តលេខ | ១៩០៦៥៥ | នាយក្រុម អ.តូចស៊ើបការណ៍ការពារ វរសេនាតូច១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤៥- | ព្រិន្ទបាលទោ | ឃិន | ចិត្រា | អត្តលេខ | ០៨៦៦២០ | នាយក្រុមរង អ.តូច២ អ.ធំ១ វរសេនាតូច១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤៦- | ព្រិន្ទបាលទោ | ហ៊ើ | សាទិ | អត្តលេខ | ១៩០៦២០ | នាយក្រុមរង អ.តូច២ អ.ធំ៣ វ.តូច១១២ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤៧- | ព្រិន្ទបាលទោ | មិត្ត | ច័ន្ទ | អត្តលេខ | ១៥០៩៥២ | នាយក្រុម អ.តូច២ អ.ធំកាំភ្លើងធំ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤៨- | ពលបាលឯក | ណុប | សំអូន | អត្តលេខ | ១៣៧៩៩៣ | នាយពួក អ.តូច៣ អ.ធំ៣ វរសេនាតូច១១១ កងពលតូចអន្តរាគមន៍លេខ១១ |
| ៤៩- | ពលបាលឯក | ខាត់ | ហួត | អត្តលេខ | ១០៨៦៦៨ | នាយពួក អ.តូច១ អ.ធំ១ វរសេនាតូច១១១ កងពលតូចអន្តរាគមន៍លេខ១១ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៥០០......សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣

# ប្រកាស

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម ÷

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំមុខងារនិងភារកិច្ចរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យថវិកា។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២
## អំពីបេសកកម្មនិងរចនាសម្ព័ន្ធ

**ប្រការ៤.-**

អគ្គនាយកដ្ឋានថវិកាបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងថវិកាជាតិ ហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋ ក្នុងគោលដៅធានាឱ្យមានការបែងចែក និងប្រើប្រាស់ធនធានថវិការដ្ឋ ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងចីរភាព។

**ប្រការ៥.-**

អគ្គនាយកដ្ឋានថវិកាមានភារកិច្ចដូចតទៅ ÷

- កសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងបទបញ្ញាហិរញ្ញវត្ថុសាធារណៈ
- រៀបចំការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ហិរញ្ញវត្ថុ បទបញ្ញាហិរញ្ញវត្ថុសាធារណៈ និងច្បាប់ដែលមានការពាក់ព័ន្ធផ្សេងទៀត
- ចូលរួមក្នុងការងារកសាងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា
- រៀបចំកម្មវិធីចំណាយសាធារណៈទៀងទាត់ ដោយផ្អែកលើកម្មវិធីចំណូលសាធារណៈ ដែលត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់ដំណើរការជាប្រចាំ និងសម្រាប់គម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្ថាប័ន ដោយផ្អែកលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ លិខិតបទដ្ឋានពាក់ព័ន្ធ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ ដែលបានទទួលការអនុម័តរួច
- ត្រួតពិនិត្យហិរញ្ញវត្ថុលើការអនុវត្តចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិ

- ចូលរួមសហការជាមួយក្រសួង ស្ថាប័ន ក្នុងការត្រួតពិនិត្យនិងតាមដានលើការអនុវត្តនីតិវិធីចំណាយ របស់រដ្ឋបាលថ្នាក់ជាតិ រួមទាំងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ
- រៀបចំអាទិភាពវិនិយោគប្រចាំឆ្នាំ សម្រាប់គោលបំណងថវិកានីយកម្មលើគម្រោងវិនិយោគសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំនិងចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានឥតសំណង ការទទួលហិរញ្ញប្បទានឥតសំណង ការឱ្យប្រាក់គេខ្ចី ការខ្ចីប្រាក់ពីគេ ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀត
- គ្រប់គ្រងនិងសម្របសម្រួលការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ
- គ្រប់គ្រងបំណុលរបស់រដ្ឋ
- ចូលរួមក្នុងការរៀបចំនិងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឯកជន
- ចូលរួមរៀបចំ តាមដាន និងត្រួតពិនិត្យលើការអនុវត្តគម្រោង ឬកិច្ចព្រមព្រៀង ឬកិច្ចសន្យាពាក់ព័ន្ធនឹងការវិនិយោគឯកជន ដែលមានការពាក់ព័ន្ធនឹងចំណាយថវិការដ្ឋ ឬកាតព្វកិច្ចបំណុលរបស់រដ្ឋ
- សហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអន្តរជាតិ ជាមួយអង្គភាពពាក់ព័ន្ធនៃអង្គការហិរញ្ញវត្ថុអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា។

**ប្រការ៦.-**

អគ្គនាយកដ្ឋានថវិកា មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម ÷

១. នាយកដ្ឋានកិច្ចការទូទៅ

២. នាយកដ្ឋានថវិកានីយកម្ម

៣. នាយកដ្ឋានហិរញ្ញកិច្ច

៤. នាយកដ្ឋានវិនិយោគ

៥. នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល។

**ប្រការ៧.-**

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

អង្គការលេខរបស់អគ្គនាយកដ្ឋានថវិកា ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

## ជំពូកទី៣

## នាយកដ្ឋានកិច្ចការទូទៅ

**ប្រការ៨.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារគ្រប់គ្រងកិច្ចការទូទៅដោយមានតួនាទីនិងភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់អគ្គនាយកដ្ឋាន
- ជាច្រកចេញ-ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់អគ្គនាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារនិងលិខិតស្នាមផ្សេងៗរបស់អគ្គនាយកដ្ឋាន

- ទទួលបន្ទុកការងារពិធីការ និងទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋាន
- ដឹកនាំការលើកគម្រោងថវិកានិងទទួលបន្ទុកការងារគណនេយ្យរបស់អគ្គនាយកដ្ឋាន នៅពេលអគ្គនាយកដ្ឋានក្លាយជាអង្គភាពថវិកា
- គ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងរៀបចំកម្មវិធីបណ្តុះបណ្តាលផ្សេងៗរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងរៀបចំកម្មវិធីប្រជុំទៀងទាត់ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន
- រៀបចំ គ្រប់គ្រង និងថែរក្សាប្រព័ន្ធព័ត៌មានវិទ្យារបស់អគ្គនាយកដ្ឋាន
- រៀបចំនិងគ្រប់គ្រងគេហទំព័ររបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងប្រមូលសរុបលទ្ធផលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋាន។

**ប្រការ៩.-**

នាយកដ្ឋានកិច្ចការទូទៅ មានការិយាល័យក្រោមឱវាទចំនួន ២ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងបុគ្គលិក

២. ការិយាល័យព័ត៌មានវិទ្យានិងសរុប។

**ប្រការ១០.-**

ការិយាល័យរដ្ឋបាលនិងបុគ្គលិកមានភារកិច្ចដូចតទៅ÷

- ជាច្រកចេញ-ចូលសម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់អគ្គនាយកដ្ឋាន
- រៀបចំលិខិតស្នាមរដ្ឋបាលនិងបោះពុម្ពឯកសារផ្សេងៗ
- ទទួលបន្ទុកការងារពិធីការនិងទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋាន
- រៀបចំគម្រោងស្នើសុំថវិការបស់អគ្គនាយកដ្ឋាន នៅពេលអគ្គនាយកដ្ឋានក្លាយជាអង្គភាពថវិកា
- គ្រប់គ្រងនិងបែងចែកសម្ភារៈប្រើប្រាស់ ឧបករណ៍ និងមធ្យោបាយផ្សេងៗរបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកការងារគណនេយ្យរបស់អគ្គនាយកដ្ឋាន នៅពេលអគ្គនាយកដ្ឋានក្លាយជាអង្គភាពថវិកា
- គ្រប់គ្រងមន្ត្រីរាជការរបស់អគ្គនាយកដ្ឋាន រាប់បញ្ចូលទាំងការគ្រប់គ្រងស្ថិតិ ការលើកយោបល់លើការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការរៀបចំប្រាក់បៀវត្សរ៍ និងការគាំពារផ្សេងៗ
- គ្រប់គ្រងវត្តមានមន្ត្រីរាជការរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងស្ថិតិបុគ្គលិកជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតរបស់អគ្គនាយកដ្ឋាន
- រៀបចំនិងសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលផ្សេងៗរបស់អគ្គនាយកដ្ឋាន។

**ប្រការ១១.-**

ការិយាល័យព័ត៌មានវិទ្យានិងសរុបមានភារកិច្ច ដូចតទៅ÷

- ផ្តល់ការគាំទ្រខាងបច្ចេកទេសព័ត៌មានវិទ្យាដល់នាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋានថវិកា
- រៀបចំនិងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការរៀបចំ ការដំឡើង និងការថែរក្សាប្រព័ន្ធបណ្តាញ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណែត នៅក្នុងអគ្គនាយកដ្ឋាន
- រៀបចំនិងបញ្ចូលទិន្នន័យផ្សេងៗ ពាក់ព័ន្ធនឹងចំណាយថវិកាចូលទៅប្រព័ន្ធបណ្តាញ

- ប្រមូលសរុបលទ្ធផលការងារ និងរៀបចំរបាយការណ៍ការងារទៀងទាត់របស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋាន។

## ជំពូកទី៤
## នាយកដ្ឋានថវិកានីយកម្ម

**ប្រការ១២.-**

នាយកដ្ឋានថវិកានីយកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារថវិកានីយកម្ម ដោយមានភារកិច្ចដូចតទៅ÷

- ដឹកនាំនិងសម្របសម្រួលកិច្ចដំណើរការបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ រួមទាំងការរៀបចំសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងសារាចរស្តីពីការរៀបចំថវិកា សម្រាប់ឆ្នាំនីមួយៗ
- រៀបចំកញ្ចប់តួលេខចំណូល និងចំណាយដំបូងរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត
- កសាងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ច្បាប់កែតម្រូវ និងបទបញ្ញានានា
- ចូលរួមរៀបចំគោលនយោបាយចំណាយថវិកា ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- ចូលរួមក្នុងដំណើរការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្នុងការកសាងតារាងប្រតិបត្តិការហិរញ្ញវត្ថុប្រចាំខែ
- ចូលរួមរៀបចំគម្រោងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- ដឹកនាំការរៀបចំកម្មវិធីចំណូល និងចំណាយប្រចាំត្រីមាសរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត ដើម្បីអនុវត្ត
- ដឹកនាំធ្វើការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំចលនាឥណទាន និងសំណើសុំបន្ថែមឥណទានរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំប្រើឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល
- ប្រមូលសរុបការអនុវត្តនិងប៉ាន់ស្មានការអនុវត្តថវិកាប្រចាំឆ្នាំ
- ចូលរួមផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ១៣.-**

នាយកដ្ឋានថវិកានីយកម្ម មានការិយាល័យក្រោមឱវាទចំនួន ៧ ដូចខាងក្រោម ÷

១. ការិយាល័យរដ្ឋបាលនិងសរុបថវិកា

២. ការិយាល័យថវិកាវិស័យរដ្ឋបាលទូទៅ

៣. ការិយាល័យថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៤. ការិយាល័យថវិកាវិស័យសង្គមកិច្ចទី១

៥. ការិយាល័យថវិកាវិស័យសង្គមកិច្ចទី២

៦. ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១

៧. ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២។

**ប្រការ១៤.-**

ការិយាល័យរដ្ឋបាលនិងសរុបថវិកា មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន
- ជាច្រកចេញ ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំសំណើកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាន
- សម្របសម្រួលគ្រប់ការិយាល័យចំណុះនាយកដ្ឋានពាក់ព័ន្ធនឹងការងាររៀបចំថវិកា តាមដានការអនុវត្តថវិកា និង ប្រមូលផ្តុំទិន្នន័យចំណូលនិងចំណាយថវិកា
- សម្របសម្រួលកិច្ចដំណើរការបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- សម្របសម្រួលការរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស សម្រាប់ការអនុវត្តថវិកា
- ដឹកនាំធ្វើការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំចលនាឥណទាន និងសំណើសុំបន្ថែមឥណទានរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំប្រើឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល
- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន។

**ប្រការ១៥.-**

ការិយាល័យថវិកាវិស័យរដ្ឋបាលទូទៅ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយ រាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងព្រះបរមរាជវាំង រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការ-បរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរសវនកម្មជាតិ អង្គភាពប្រឆាំងអំពើពុករលួយ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ១៦.-**

ការិយាល័យថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ តុលាការកំពូល សាលាឧទ្ធរណ៍ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**ប្រការ១៧.-**

ការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញ ខ្សែបណ្តោយ រាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងធម្មការ និងសាសនា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ១៨.-**

ការិយាល័យថវិកាវិស័យសង្គមកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញ ខ្សែបណ្តោយ រាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង

ក្រសួងកិច្ចការនារី។

**ប្រការ១៩.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយ រាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងធនធានទឹកនិងឧតុនិយម។

**ប្រការ២០.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយ រាជធានី ខេត្ត ដែលរួមមាន÷ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងទេសចរណ៍។

**ប្រការ២១.-**

ការិយាល័យថវិកាវិស័យរដ្ឋបាលទូទៅ ការិយាល័យថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ ការិយាល័យថវិកាវិស័យសង្គមកិច្ចទី២ ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១និង ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រៀងៗខ្លួន ដោយមានភារកិច្ច ដូចតទៅ÷

- រៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត
- សហការក្នុងកិច្ចដំណើរការបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- សហការរៀបចំសារាចរស្តីពីការកសាងគម្រោងចំណូលនិងចំណាយថវិកាជាតិប្រចាំឆ្នាំនីមួយៗ
- រៀបចំតួលេខត្រួតពិនិត្យចំណូល-ចំណាយថវិកាឱ្យក្រសួង ស្ថាប័ន និងមន្ទីរជំនាញខ្សែបណ្តោយ រាជធានី ខេត្ត ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងដើម្បីអនុវត្ត
- សហការជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំកសាងផែនការថវិកាប្រចាំឆ្នាំរបស់មន្ទីរជំនាញខ្សែបណ្តោយ រាជធានី ខេត្ត
- សហការក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ
- កត់ត្រា តាមដានជាប្រចាំនិងទៀងទាត់ លើការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញខ្សែបណ្តោយ រាជធានី ខេត្ត
- ពិនិត្យនិងផ្តល់យោបល់ លើសំណើចលនាឥណទាន និងសំណើសុំឥណទានបន្ថែមរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត
- បូកសរុបសភាពការណ៍អនុវត្តថវិកា ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ចូលរួមផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត។

## ជំពូកទី៥

## នាយកដ្ឋានហិរញ្ញកិច្ច

**ប្រការ២២.-**

នាយកដ្ឋានហិរញ្ញកិច្ច បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារហិរញ្ញកិច្ច ដោយមានភារកិច្ច ដូចតទៅ ÷

- អនុវត្តការងារត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គភាពសាធារណៈរដ្ឋបាល
- អនុវត្តការងារពាក់ព័ន្ធបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- គ្រប់គ្រងសកម្មភាព សម្របសម្រួល និងតាមដានការអនុវត្តរបស់អភិបាលហិរញ្ញវត្ថុ
- កត់ត្រាជាប្រចាំ និងបូកសរុបទៀងទាត់ នូវកិច្ចសន្យាចំណាយ
- ពិនិត្យនិងផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើសំណើសុំចំណាយថវិការបស់ក្រសួង ស្ថាប័ន
- ត្រួតពិនិត្យការអនុវត្តចំណាយថវិការបស់ក្រសួង ស្ថាប័ន
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលទំនិញ សម្ភារៈ បរិក្ខា សេវា និងសំណង់
- ពិនិត្យនិងផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើគ្រប់សំណើសុំបុរេប្រទានថវិការបស់ក្រសួង ស្ថាប័ន ចំណាយតាមការចាំបាច់ជាក់ស្តែង
- ផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់
- ផ្តល់យោបល់បច្ចេកទេសដល់អាណាប័ក ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ
- ផ្តល់កិច្ចសហការក្នុងការរៀបចំថវិកា និងច្បាប់ហិរញ្ញវត្ថុ។

**ប្រការ២៣.-**

នាយកដ្ឋានហិរញ្ញកិច្ច មានការិយាល័យក្រោមឱវាទចំនួន ៧ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងសរុប

២. ការិយាល័យហិរញ្ញកិច្ចវិស័យរដ្ឋបាលទូទៅ

៣. ការិយាល័យហិរញ្ញកិច្ចវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៤. ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី១

៥. ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី២

៦. ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១

៧. ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២។

**ប្រការ២៤.-**

ការិយាល័យរដ្ឋបាលនិងសរុប មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន
- ជាច្រកចេញ ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំសំណើកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាន
- ជាចំណុចសម្របសម្រួលនិងប្រមូលផ្តុំទិន្នន័យ ពាក់ព័ន្ធនឹងការងារអនុវត្តថវិកា
- ទទួលបន្ទុកធ្វើសំយោគរបាយការណ៍ទាំងអស់ ដែលទទួលបានពីគ្រប់ការិយាល័យគ្រប់គ្រងហិរញ្ញកិច្ច ស្តីពីការអនុវត្តថវិការដ្ឋ ដែលមានជាអាទិ៍ របាយការណ៍ធានាចំណាយ និងរបាយការណ៍ចេញអាណត្តិបើកប្រាក់
- សម្របសម្រួលការកសាងនីតិវិធី និងបទដ្ឋានចំណាយផ្សេងៗ សម្រាប់អនុវត្តជាទូទៅ

- ចូលរួមរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស សម្រាប់ការអនុវត្តថវិកា
- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន។

**ប្រការ២៥.-**

ការិយាល័យគ្រប់គ្រងហិរញ្ញកិច្ចវិស័យរដ្ឋបាលទូទៅ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ ក្រសួងព្រះបរមរាជវាំង រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរសវនកម្មជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ។

**ប្រការ២៦.-**

ការិយាល័យហិរញ្ញកិច្ចវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ តុលាការកំពូល សាលាឧទ្ធរណ៍ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**ប្រការ២៧.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័នដែលរួមមាន÷ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងធម្មការនិងសាសនា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ២៨.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី។

**ប្រការ២៩.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងធនធានទឹកនិងឧតុនិយម។

**ប្រការ៣០.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័នដែលរួមមាន÷ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងទេសចរណ៍។

**ប្រការ៣១.-**

ការិយាល័យហិរញ្ញកិច្ចវិស័យរដ្ឋបាលទូទៅ ការិយាល័យហិរញ្ញកិច្ចវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី១ ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី២ ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១ និងការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រៀងៗខ្លួន ដោយមានភារកិច្ចដូចតទៅ ÷

- តាមដាននិងសម្របសម្រួលសកម្មភាពអនុវត្តរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
- ប្រមូលផ្តុំព័ត៌មាន និងទិន្នន័យនៃសទ្យាចំណាយ ការប្រើប្រាស់ឥណទាន និងការបញ្ចេញអាណត្តិ

- ធ្វើសំយោគរបាយការណ៍របស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ស្តីពីការអនុវត្តចំណាយថវិការដ្ឋ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងការប្រតិបត្តិនៃកិច្ចសន្យាគម្រោង ដើម្បីលើកយោបល់អំពីវិធានការចាំបាច់ដែលត្រូវធ្វើការកែលម្អ កែទម្រង់ សំដៅលុបបំបាត់កង្វះខាតទាំងឡាយ ដែលកត់សម្គាល់ឃើញជាយថាហេតុ
- ចូលរួមក្នុងការរៀបចំកម្មវិធីចំណូល ចំណាយសាធារណៈប្រចាំខែ ត្រីមាស និងអនុវត្តកម្មវិធីនេះ ឱ្យបានខ្ជាប់ខ្ជួន
- ចូលរួម និងសិក្សាអំពីតម្រូវការចំណាយនានារបស់ក្រសួង ស្ថាប័ន សម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំនីមួយៗ និងសម្រាប់ការរៀបចំកម្មវិធីចំណាយរយៈពេលមធ្យម
- ពិនិត្យនិងផ្តល់យោបល់លើសំណើសុំបុរេប្រទានថវិការបស់ក្រសួង ស្ថាប័នចំណាយ។

**ប្រការ៣២.-**

នាយកដ្ឋានហិរញ្ញកិច្ច មានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នៅអមក្រសួង ស្ថាប័ននីមួយៗ ដែលអាចមានចំនួនមួយរូប ឬច្រើនរូប។

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធានការិយាល័យ ដែលអមដោយអនុប្រធានមួយចំនួន ជាជំនួយការ ឋានៈស្មើអនុប្រធានការិយាល័យ។

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៣៣.-**

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន មានភារកិច្ចដូចខាងក្រោម÷

- ត្រួតពិនិត្យហិរញ្ញវត្ថុនៃការអនុវត្តចំណាយរបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធនឹងប្រសិទ្ធភាព ភាពចាំបាច់ និងភាពត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីហិរញ្ញវត្ថុ
- ពិនិត្យនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួង ក្នុងការផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់
- ផ្តល់ប្រឹក្សាជាប្រចាំ អំពីនីតិវិធីចំណាយ ចំពោះផ្នែកនានារបស់អាណាប័ក
- ពិនិត្យនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួង លើរាល់សំណើសុំថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលចំណុះក្រសួង ស្ថាប័ន
- ត្រួតពិនិត្យប្រតិបត្តិការហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលទំនិញ សម្ភារៈ បរិក្ខា សេវា និងសំណង់
- ចូលរួមក្នុងដំណើរការរៀបចំថវិការបស់ក្រសួង ស្ថាប័ន
- កាន់កាប់បញ្ជីគណនេយ្យសន្យាចំណាយ និងអាណត្តិកិច្ចតាមលក្ខខណ្ឌ ដូចខាងក្រោម÷
  - គណនេយ្យចំណាយវលញ្ជិក សម្រាប់ចំណាយចុះកិច្ចសន្យា
  - គណនេយ្យចំណាយអាណាប័ណ្ណ សម្រាប់អាណត្តិបើកប្រាក់។

## ជំពូកទី៦

## នាយកដ្ឋានវិនិយោគ

**ប្រការ៣៤.-**

នាយកដ្ឋានវិនិយោគ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារវិនិយោគ ដោយមានភារកិច្ចដូចតទៅ ÷

- ចូលរួមរៀបចំគោលនយោបាយចំណាយវិនិយោគសាធារណៈ និងចំណាយថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- គ្រប់គ្រងឥណទានថវិកាគម្រោងវិនិយោគផ្ទាល់ និងឥណទានថវិកាថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- ចូលរួមជាមួយក្រសួង ស្ថាប័ន រៀបចំផែនការចំណាយវិនិយោគសាធារណៈ និងផែនការចំណាយ ថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ សម្រាប់គោលបំណងថវិកានីយកម្ម
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈ ដោយផ្អែកលើកម្មវិធីចំណាយ
- ត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយវិនិយោគសាធារណៈ និងចំណាយថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលសម្ភារៈ បរិក្ខា សេវា និងសំណង់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យ និង វាយតម្លៃលទ្ធផលការងាររបស់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនីមួយៗ
- ចូលរួមក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ចូលរួមក្នុងការងាររៀបចំនិងអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឯកជន
- ចូលរួមរៀបចំ តាមដាន និងត្រួតពិនិត្យលើការអនុវត្តគម្រោង ឬកិច្ចព្រមព្រៀង ឬកិច្ចសន្យាពាក់ព័ន្ធនឹងការវិនិយោគឯកជន ដែលមានពាក់ព័ន្ធនឹងចំណាយថវិការដ្ឋ ឬដែលមានពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលរបស់រដ្ឋ។

**ប្រការ៣៥.-**

នាយកដ្ឋានវិនិយោគមានការិយាល័យក្រោមឱវាទចំនួន ៦ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងសរុប

២. ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី១

៣. ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី២

៤. ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី៣

៥. ការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ

៦. ការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន

**ប្រការ៣៦.-**

ការិយាល័យរដ្ឋបាលនិងសរុប មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន
- ជាច្រកចេញ ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំសំណើកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាន
- ជាចំណុចសម្របសម្រួលនិងប្រមូលផ្តុំទិន្នន័យពាក់ព័ន្ធនឹងការងារអនុវត្តថវិកា
- ទទួលបន្ទុកធ្វើសំយោគរបាយការណ៍ទាំងអស់ ដែលទទួលបានពីគ្រប់ការិយាល័យជំនាញ ស្តីពីការអនុវត្តថវិការដ្ឋ ដែលមានជាអាទិ៍របាយការណ៍ធានាចំណាយ និងរបាយការណ៍ចេញអាណត្តិបើកប្រាក់
- គ្រប់គ្រងឥណទានថវិកាវិនិយោគផ្ទាល់ និងឥណទានថវិកាថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- បូកសរុបរបាយការណ៍ចំណាយ និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀតរបស់នាយកដ្ឋាន

- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន។

**ប្រការ៣៧.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី១ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន ដែលរួមមាន ក្រសួងព្រះបរមរាជវាំង រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសុខាភិបាល ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងធម្មការនិងសាសនា ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរសវនកម្មជាតិ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពប្រឆាំងអំពើពុករលួយ។

**ប្រការ៣៨.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី២ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន ដែលរួមមាន រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងទេសចរណ៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៣៩.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី៣ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន ដែលរួមមាន ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងធនធានទឹក និងឧតុនិយម។

**ប្រការ៤០.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី១ ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី២ និងការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី៣ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន រៀងៗខ្លួន ដោយមានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយចំណាយវិនិយោគសាធារណៈ សម្រាប់គោលបំណងថវិកានីយកម្ម ដោយត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ចូលរួមជាមួយក្រសួង ស្ថាប័ន រៀបចំផែនការចំណាយវិនិយោគ សម្រាប់គោលបំណងថវិកានីយកម្ម
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈ ដោយផ្អែកលើកម្មវិធីចំណាយ
- ត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយគម្រោងវិនិយោគសាធារណៈ
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលសម្ភារៈ បរិក្ខា សេវា និងសំណង់
- ចូលរួមក្នុងដំណើរការរៀបចំថវិការបស់ក្រសួង ស្ថាប័ន
- រៀបចំរបាយការណ៍ទៀងទាត់ នៃចំណាយគម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្ថាប័ន។

**ប្រការ៤១.-**

ការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដូចជា ផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធធារាសាស្ត្រ ដោយត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ចូលរួមរៀបចំផែនការចំណាយថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ សម្រាប់គោលបំណងថវិកានីយកម្ម
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដោយផ្អែកលើកម្មវិធីចំណាយដែលបានអនុម័តរួច
- ត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលសម្ភារៈ បរិក្ខា សេវា និងសំណង់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យ និងវាយតម្លៃលទ្ធផលការងាររបស់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនីមួយៗ
- ចូលរួមក្នុងដំណើរការរៀបចំថវិការបស់ក្រសួង ស្ថាប័ន
- រៀបចំរបាយការណ៍ទៀងទាត់ នៃចំណាយគម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្ថាប័ន។

**ប្រការ៤២.-**

ការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច ហៅថាក្រុម "ឃ" និងអនុគណៈកម្មការបរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ
- ចូលរួមក្នុងដំណើរការរៀបចំ និងអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឯកជន
- ចូលរួមក្នុងដំណើរការរៀបចំ អនុម័ត តាមដាន និងត្រួតពិនិត្យលើការអនុវត្តគម្រោងឬកិច្ចព្រមព្រៀង ឬកិច្ចសន្យាក្រោមគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលមានការធានាពីរដ្ឋ ឬដែលមានការពាក់ព័ន្ធនឹងចំណាយថវិការដ្ឋ ឬដែលមានការពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលរបស់រដ្ឋ
- ចូលរួមក្នុងកិច្ចប្រជុំច្រកចេញ-ចូលតែមួយ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

## ជំពូកទី៧

## នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល

**ប្រការ៤៣.-**

នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកាលើការងារសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល ដោយមានភារកិច្ចដូចតទៅ ÷

- ទទួលខុសត្រូវលើការងារកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអន្តរជាតិជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគីនិងពហុភាគី
- រៀបចំនិងអនុវត្តគោលនយោបាយឬកម្មវិធីទទួលហិរញ្ញប្បទានសហប្រតិបត្តិការនិងចំណាយថវិកាបដិភាគ
- ចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការងារសិក្សាសមិទ្ធិលទ្ធភាព និងការងាររៀបចំគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- ចូលរួមគ្រប់គ្រងនិងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- តាមដាននិងត្រួតពិនិត្យលើការប្រើប្រាស់ថវិកាបដិភាគ
- គ្រប់គ្រងគណនីគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍

- រៀបចំនិងចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ពាក់ព័ន្ធនឹងការផ្តល់និងការទទួលហិរញ្ញប្បទានឥតសំណង ការឱ្យប្រាក់គេខ្ចី និងការខ្ចីប្រាក់ពីគេ ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀត
- គ្រប់គ្រងចំណូលពីហិរញ្ញប្បទានឥតសំណង ពីការខ្ចីប្រាក់ពីគេ និងពីការសងបំណុលរបស់សហគ្រាសសាធារណៈនិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលរដ្ឋឱ្យខ្ចី
- គ្រប់គ្រងប្រព័ន្ធទិន្នន័យបំណុលសាធារណៈរបស់រដ្ឋគ្រប់ប្រភេទ ទាំងបំណុលក្រៅប្រទេស ក្នុងប្រទេស និងកាតព្វកិច្ចបំណុលជាយថាហេតុ និងហានិភ័យបំណុលពាក់ព័ន្ធផ្សេងទៀត។

**ប្រការ៤៤.-**

នាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល មានការិយាល័យក្រោមឱវាទចំនួន ៥ ដូចខាងក្រោម ÷

១. ការិយាល័យគ្រប់គ្រងបំណុល រដ្ឋបាល និងសរុប

២. ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី១

៣. ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី២

៤. ការិយាល័យសហប្រតិបត្តិការពហុភាគីទី១

៥. ការិយាល័យសហប្រតិបត្តិការពហុភាគីទី២។

**ប្រការ៤៥.-**

ការិយាល័យគ្រប់គ្រងបំណុល រដ្ឋបាល និងសរុប មានភារកិច្ចដូចតទៅ÷

- រៀបចំនិងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ
- ចាត់ចែងការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុលសាធារណៈ
- ព្យាករណ៍និងចាត់ចែងអនុវត្តការទូទាត់សេវាបំណុលសាធារណៈ
- វិភាគចីរភាពបំណុលសាធារណៈរបស់រដ្ឋ
- ដឹកនាំការងារផ្ទៀងផ្ទាត់ទិន្នន័យបំណុលសាធារណៈ ជាមួយការិយាល័យពាក់ព័ន្ធនៃនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល និងជាមួយអង្គភាពពាក់ព័ន្ធផ្សេងទៀត
- ចូលរួមគ្រប់គ្រងនិងវិភាគលើការធានារបស់រដ្ឋ ដែលអាចនាំឱ្យកើតមានបំណុលសាធារណៈ
- ចាត់ចែងការគ្រប់គ្រងសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ
- គ្រប់គ្រងចំណូលពីការសងបំណុលរបស់សហគ្រាសសាធារណៈនិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលរដ្ឋឱ្យខ្ចី
- ចូលរួមក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- គ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុ និងហានិភ័យបំណុលពាក់ព័ន្ធផ្សេងទៀត
- បូកសរុបរបាយការណ៍ចំណូល-ចំណាយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- ជាច្រកចេញ ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំសំណើកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាន
- ជាចំណុចសម្របសម្រួលនិងប្រមូលផ្តុំទិន្នន័យពាក់ព័ន្ធការងារអនុវត្តថវិកា
- គ្រប់គ្រងឥណទានថវិកាសេវាបំណុល ឥណទានថវិកាបដិភាគ និងមូលនិធិទ្រទ្រង់ថវិកា

- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន។

**ប្រការ៤៦.-**

ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី១ ទទួលបន្ទុកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយប្រទេសជប៉ុន ប្រទេសកូរ៉េ និងប្រទេសមិនមែនអាស៊ី។

**ប្រការ៤៧.-**

ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី២ ទទួលបន្ទុកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយប្រទេសអាស៊ី លើកលែងប្រទេសជប៉ុននិងប្រទេសកូរ៉េ។

**ប្រការ៤៨.-**

ការិយាល័យសហប្រតិបត្តិការពហុភាគីទី១ ទទួលបន្ទុកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយធនាគារអភិវឌ្ឍន៍អាស៊ីនិងមូលនិធិអូប៉ិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ។

**ប្រការ៤៩.-**

ការិយាល័យសហប្រតិបត្តិការពហុភាគីទី២ ទទួលបន្ទុកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយក្រុមធនាគារពិភពលោកនិងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍពហុភាគីផ្សេងទៀត។

**ប្រការ៥០.-**

ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី១ ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី២ ការិយាល័យសហប្រតិបត្តិការពហុភាគីទី១ និងការិយាល័យសហប្រតិបត្តិការពហុភាគីទី២ ទទួលបន្ទុកការងារសហប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍រៀងៗខ្លួន ដោយមានភារកិច្ចដូចតទៅ÷

- ចូលរួមក្នុងការងាររៀបចំនិងអនុវត្តគោលនយោបាយ ឬកម្មវិធីទទួលហិរញ្ញប្បទានសហប្រតិបត្តិការនិងចំណាយថវិកាបដិភាគ
- ចូលរួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការងារសិក្សាសមិទ្ធិលទ្ធភាព និងការងាររៀបចំគម្រោងដើម្បីស្នើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងនិងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទាន ពីដៃគូអភិវឌ្ឍន៍តាមរយៈការត្រួតពិនិត្យការទូទាត់ និងការងារលទ្ធកម្ម ចំពោះគម្រោងដែលត្រូវអនុវត្តនីតិវិធីដៃគូអភិវឌ្ឍន៍
- តាមដាននិងត្រួតពិនិត្យជាប្រចាំ លើការប្រើប្រាស់មូលនិធិថវិកាបដិភាគ
- គ្រប់គ្រងគណនីគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍
- រៀបចំនិងចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋជាមួយដៃគូអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងការទទួលឬការផ្តល់ហិរញ្ញប្បទានឥតសំណង ការខ្ចីប្រាក់ពីគេ ឬការឱ្យប្រាក់គេខ្ចី ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀត
- កសាងផែនការចំណូលពីហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទាន
- ចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈនិងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ត្រួតពិនិត្យមួងម្កាលលើនីតិវិធីគ្រប់គ្រងនិងអនុវត្តគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ដូចជានីតិវិធីដកសាច់ប្រាក់ នីតិវិធីលទ្ធកម្ម និងនីតិវិធីចំណាយផ្សេងៗ
- ធ្វើបញ្ជិកាប្រតិបត្តិការហិរញ្ញវត្ថុគម្រោងហិរញ្ញប្បទានដោយដៃគូនិងថវិកាបដិភាគ

- រៀបចំរបាយការណ៍ពាក់ព័ន្ធ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ៥១.-**

ក្នុងពេលបំពេញការងារ ភារកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញដទៃ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬស្នើសុំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការកំណត់ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ៥២.-**

ប្រកាសនេះ ត្រូវជំនួសប្រកាសដូចខាងក្រោម÷

- ប្រកាសលេខ ៩៧៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ
- ប្រកាសលេខ ១៥៥ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានថវិកា
- ប្រកាសលេខ ១៥៦ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានហិរញ្ញកិច្ច។

**ប្រការ៥៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៥៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

៤

ឧបសម្ព័ន្ធទី១
នៃប្រកាសលេខ ១៥០០ សហវ.ប្រក
ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ
នៃនាយកដ្ឋាននិងអង្គភាព
ក្រោមឱវាទអគ្គនាយកដ្ឋានថវិកា
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# អង្គការលេខនៃអគ្គនាយកដ្ឋានថវិកា

- **អគ្គនាយក**
  - **អគ្គនាយករង**
    - នាយកដ្ឋាន កិច្ចការទូទៅ
      - ការិយាល័យ រដ្ឋបាល និង បុគ្គលិក
      - ការិយាល័យ ពត៌មានវិទ្យា និងសរុប
    - នាយកដ្ឋាន ថវិកានីយកម្ម
      - ការិយាល័យរដ្ឋបាល និងសរុបថវិកា
      - ការិយាល័យថវិកា វិស័យរដ្ឋបាលទូទៅ
      - ការិយាល័យថវិកាវិស័យ ការពារជាតិ សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ
      - ការិយាល័យថវិកាវិស័យ សង្គមកិច្ចទី១
      - ការិយាល័យថវិកាវិស័យ សង្គមកិច្ចទី២
      - ការិយាល័យថវិកាវិស័យ សេដ្ឋកិច្ចទី១
      - ការិយាល័យថវិកាវិស័យ សេដ្ឋកិច្ចទី២
    - នាយកដ្ឋាន ហិរញ្ញកិច្ច
      - ការិយាល័យ រដ្ឋបាល និងសរុប
      - ការិយាល័យហិរញ្ញកិច្ច វិស័យរដ្ឋបាលទូទៅ
      - ការិយាល័យហិរញ្ញកិច្ច វិស័យការពារជាតិ សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ
      - ការិយាល័យហិរញ្ញកិច្ច វិស័យសង្គមកិច្ចទី១
      - ការិយាល័យហិរញ្ញកិច្ច វិស័យសង្គមកិច្ចទី២
      - ការិយាល័យហិរញ្ញកិច្ច វិស័យសេដ្ឋកិច្ចទី១
      - ការិយាល័យហិរញ្ញកិច្ច វិស័យសេដ្ឋកិច្ចទី២
    - នាយកដ្ឋាន វិនិយោគ
      - ការិយាល័យ រដ្ឋបាល និងសរុប
      - ការិយាល័យ វិនិយោគសាធារណៈ ក្នុងស្រុកទី១
      - ការិយាល័យ វិនិយោគសាធារណៈ ក្នុងស្រុកទី២
      - ការិយាល័យ វិនិយោគសាធារណៈ ក្នុងស្រុកទី៣
      - ការិយាល័យ ថែទាំហេដ្ឋារចនា សម្ព័ន្ធសាធារណៈ
      - ការិយាល័យ សម្របសម្រួលការ អភិវឌ្ឍផ្តែកឯកជន
    - នាយកដ្ឋាន សហប្រតិបត្តិការ និងគ្រប់គ្រងបំណុល
      - ការិយាល័យ គ្រប់គ្រងបំណុល រដ្ឋបាល និងសរុប
      - ការិយាល័យ សហប្រតិបត្តិការ ទ្វេភាគីទី១
      - ការិយាល័យ សហប្រតិបត្តិការ ទ្វេភាគីទី២
      - ការិយាល័យ សហប្រតិបត្តិការ ពហុភាគី១
      - ការិយាល័យ សហប្រតិបត្តិការ ពហុភាគី២

## ឧបសម្ព័ន្ធទី២

## នៃប្រកាសលេខ១៥០០សហវ.ប្រក ចុះថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានដូចតទៅ ÷

១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងព្រះបរមរាជវាំង
២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ព្រឹទ្ធសភា
៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម រដ្ឋសភា
៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រុមប្រឹក្សាធម្មនុញ្ញ
៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម អាជ្ញាធរសវនកម្មជាតិ
៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ទីស្តីការគណៈរដ្ឋមន្ត្រី
៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមុខងារសាធារណៈ
៩- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
១០- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងយុត្តិធម៌
១១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
១២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច
១៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
១៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងផែនការ
១៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ
១៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការពារជាតិ
១៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ
១៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
១៩- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងទេសចរណ៍
២០- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
២១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងអភិវឌ្ឍន៍ជនបទ
២៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងធនធានទឹក និងឧតុនិយម
២៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងសាធារណការ និងដឹកជញ្ជូន

២៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់
២៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងពាណិជ្ជកម្ម
២៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
២៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
២៩- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងព័ត៌មាន
៣០- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងបរិស្ថាន
៣១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសុខាភិបាល
៣២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងអប់រំ យុវជន និងកីឡា
៣៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
៣៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងធម្មការ និងសាសនា
៣៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងកិច្ចការនារី
៣៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
៣៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម អង្គភាពប្រឆាំងអំពើពុករលួយ
៣៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងរ៉ែនិងថាមពល។